ឯកសារគម្ពីរព្រះត្រៃបិដកស្កេនដេះ
ត្រូវបានថតចេញពី ច្បាប់គម្ពីរព្រះត្រៃបិដកជប៉ុន ៗ

ឯកសារគម្ពីរព្រះត្រៃបិដកនេះ ចាប់ពីភាគ៥១ ដល់ ភាគ១១០
ត្រូវបានរៀបចំធ្វើឡើងដោយ គេហទំព័រ៥០០០ឆ្នាំ បូជា
ចំពោះព្រះពុទ្ធសាសនា សម្រាប់ជាធម្មទាន ៗ

ផ្តល់សៀវភៅគម្ពីរព្រះត្រៃបិដកសម្រាប់ការងារ
ដោយ ឧបាសិកា កាំង ហ្គិចណៃ ៗ

គ្រប់គ្រងគម្រោង (ទូទៅ និងផ្នែកបច្ចេកទេស)
ដោយ ឧបាសក ស្រុង-ចាន់ណា ៗ

ត្រួតពិនិត្យឡើងវិញ
ដោយ ចន-ស្រីស្រស់ ៗ

ថតស្កេនដោយ
ប្អូនប្រុស ម៉ាន់ សាវ៉េត

www.5000-years.org

ក្រោមការឧបត្ថម្ភយ៉ាងច្រើនពីៈ

- ឧបាសិកា កាំង ហ៊ុចណៃ (ភ្នំពេញ)
- ឧបាសក ជុត លីស្រ៊ុង និង ឧបាសិកា លី សុខា ព្រមទាំងបុត្រ (ភ្នំពេញ)
- ឧបាសក សរ ចន និង ឧបាសិកា អ៊ីច សាវៀង ព្រមទាំងបុត្រ (បាត់ដំបង)
- ឧបាសក ជា ស៊ុវត្ថានា និងឧបាសិកា ឃុន សូនីម៉ា ព្រមទាំងបុត្រី ជា សុមេធាធីតា (ស.រ.អ)
- លោក ជីម-ជា និងលោកស្រី រតនី ស្រីមុំ (ភ្នំពេញ)
- ឧបាសក ជែង យឿន (កូរ៉េ)
- លោក ស៊ុក ចាន់សេរី (បន្ទាយមានជ័យ)
- ឧបាសិកា យ៉ា រ៉ាវី (បន្ទាយមានជ័យ)
- ប្អូនស្រី យ៉ា សុភៈ (បន្ទាយមានជ័យ)
- ឧបាសិកា កោ សេង (ភ្នំពេញ)
- លោកស្រី ប៉ាន សុគន្ធានីន និងស្វាមី ព្រមទាំងបុត្រ (ភ្នំពេញ)
- ឧបាសក ស្រ៊ុង ចាន់ណា និង ឧបាសិកា ចន ស្រីស្រស់
ព្រមទាំងបុត្រ ចាន់ណា សុធារនីរាជ, ចាន់ណា សុធារនិរោធ (ភ្នំពេញ)
- លោកស្រី ស្រ៊ុង ចាន់រស្មី និង ស្វាមី ព្រមទាំងបុត្រ (ភ្នំពេញ)
- កញ្ញា ស្រ៊ុង ចាន់រតនា (ភ្នំពេញ)
- លោក ស្រ៊ុង យូហេង (ភ្នំពេញ)
- លោក នង សុផល (កូរ៉េ)
- ប្អូនស្រី សុខ អេង (កំពង់ចាម)
- កញ្ញា ចន កក្កដា (បាត់ដំបង)
- លោកស្រី ចន សត្យា និងលោក ទូត សេរីស័ក ព្រមទាំងបុត្រ (ភ្នំពេញ)
- លោក ចន រចនា (បាត់ដំបង)
- កញ្ញា ស៊ែ សុផារី (បាត់ដំបង)
- កញ្ញា យឿម សុផានី (បាត់ដំបង)
- លោក ម៉ៅ គន្ធា និងលោកស្រី ធៀង សេដ្ឋា (បាត់ដំបង)
- លោក សៅ សារ៉ុម (បាត់ដំបង)
- ព្រះតេជព្រះគុណ ជុំ សារៈ (ព្រះចៅអធិការវត្ត សម សាន្ត ខេត្តបាត់ដំបង)

# ព្រះ
# ត្រៃបិដកបាលី
## និង
# សេចក្ដីប្រែជាភាសាខ្មែរ
# អភិធម្មបិដក
# ធម្មសង្គណី បឋមភាគ
# ៧៨

ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

ព.ស. ២៥០៧

## ឧទ្ទិសកថា

យើងខ្ញុំ សូមផ្តល់ស្មារតីសូត្រព្រះធម៌ឧទ្ទិសជូនជនជាតិខ្មែរ ។
ឥឡូវ យើងខ្ញុំអាចជូនគម្ពីរព្រះត្រៃបិដកនេះ ទៅអ្នកកាន់ព្រះពុទ្ធសាសនាជនជាតិខ្មែរបានហើយ ។
ព្រះធម៌នៃព្រះពុទ្ធជាម្ចាស់នេះ ត្រូវបានសូត្រចេញពីជម្រៅដួងចិត្តនៃអ្នកកាន់ព្រះពុទ្ធសាសនាជនជាតិជប៉ុន ។

このカンボジア版南伝大蔵経を
カンボジアの佛教徒へ
贈ることができることに感謝します。
これが日本の佛教徒の心です。

It is with a deep sense of gratitude that I present the translation of the complete TRIPITAKA to Cambodian Buddhists on behalf of the Japanese Buddhist community.

# អារម្ភកថា

ជូនចំពោះជនជាតិខ្មែរ ជាទីរាប់អាន !
ជូនចំពោះជនជាតិខ្មែរដែលកាន់ព្រះពុទ្ធសាសនា ជាទីគោរព !

គម្ពីរព្រះត្រៃបិដកខ្មែរនេះ ត្រូវបាន " ក្រុមជំនុំព្រះត្រៃបិដក " នៃពុទ្ធសាសនបណ្ឌិត្យ នៅភ្នំពេញ បកប្រែពីភាសាបាលីមកជាភាសាខ្មែរ តាំងពីឆ្នាំ ១៩៣០ ទៅឆ្នាំ ១៩៦៨ គឺត្រូវចំណាយពេល ៣៩ ឆ្នាំ ទើបបានសម្រេចហើយសព្វគ្រប់ ។ នេះពិតជាកំណាប់ព្រះធម៌របស់ព្រះពុទ្ធសាសនាខ្មែរ ហើយក៏ជាកំណាប់វប្បធម៌ខាងផ្នែកបោះពុម្ពរបស់ជនជាតិខ្មែរផងដែរ ។ យើងខ្ញុំ ពុទ្ធសាសនិកជាតិជប៉ុន មានសន្ដានចិត្តរីករាយនឹងបោះពុម្ពជាថ្មីឡើងវិញ ដោយសង្ឃឹមថា ព្រះពុទ្ធសាសនាខ្មែរក៏នឹងរុងរឿងឡើងវិញដែរ ។

នេះគឺជាអំណោយពីជម្រៅដួងចិត្ត ជូនទៅដល់ជនជាតិខ្មែរទាំងអស់ ព្រមទាំងមនុស្សជាតិទូទៅ នៅក្នុងពិភពលោកនេះ ដែលមានចិត្តស្រឡាញ់សន្តិភាព ។

ខ្មែរបានរងសោកនាដកម្មដែលមិនធ្លាប់មានពីមុនមក ។ ម្យ៉ាងទៀត ព្រះពុទ្ធសាសនាខ្មែរ ក៏ត្រូវអន្តរាយយ៉ាងខ្លាំង ក៏ប៉ុន្តែឥឡូវនេះ យើងទាំងអស់គ្នា បានឈានជើងកន្លងផុតពីសេចក្ដីទុក្ខសោកដ៏ធ្ងន់ធ្ងរនេះ ចាកផុតពីអំពើឃោរឃៅ បញ្ចប់គំនុំគុំគួន ដើរតាមពុទ្ធដីកាព្រះបរមគ្រូ ខិតខំព្យាយាមធ្វើឱ្យមានសន្តិភាពក្នុងពិភពលោក ។

ការណ៍ដែលយើងខ្ញុំជូនគម្ពីរព្រះត្រៃបិដកពេលនេះ គឺជានិមិត្តរូបនៃការប្ដេជ្ញាចិត្តរបស់អ្នកកាន់ព្រះពុទ្ធសាសនាជនជាតិជប៉ុនថា យើងខ្ញុំធ្វើសហប្រតិបត្តិការដើម្បីសន្តិភាពក្នុងពិភពលោក ដើម្បីទុកជាភស្តុតាងនៃចំណងមេត្រីភាព និងមិត្តភាពរវាងប្រជាជាតិជប៉ុន និងប្រជាជាតិខ្មែរ ។

ថ្ងៃនក្ខត្តឫក្ស កក្កដា ឆ្នាំ ១៩៩៤

សមាគមជំនួយដល់ការបោះពុម្ពព្រះត្រៃបិដកឡើងវិញ
អ្នកតំណាងចាត់ការ The Rev. Seikyo Muchaku
ប្រធានការិយាល័យ The Rev. Eiitsu Shinohara
អ្នកចាត់ការ
The Rev. Zendo Matsunaga The Rev. Jitsujo Arima The Rev. Yoshimichi Ito
The Rev. Keiichi Watai The Rev. Gijun Sugitani The Rev. Shincho Shigeta
The Rev. Risho Maeda The Rev. Kyoshi Nakajima Mr. Rokusuke Ei

# 『トリピタカ』復刻進呈にあたって

親愛なるカンボジアの皆さん！
敬愛するカンボジアの仏教徒の皆さん！

カンボジア版『トリピタカ』は、プノンペンの仏教研究所が、仏教界の英知を集め、1930年から1968年まで、39年の歳月をかけて翻訳し、分類し、集大成して完成されました。まさにカンボジア仏教の法宝であると共に、カンボジア出版文化の至宝です。日本仏教徒の有志は、カンボジア仏教の復興再生を願いつつ、これを復刻刊行し、贈らせていただきます。

これはカンボジア仏教徒のみならず、カンボジア全人民、否、平和を愛する地球上のすべての人々への、心からの贈り物です。

カンボジアは、古今未曾有の悲劇を体験しました。カンボジア仏教もこの受難の時代に壊滅的な打撃を受けました。しかし、今はその悲しみを乗りこえ、瞋りを離れ、怨みを恕し、ブッダの教えに従い、世界平和の実現に努力するときです。

この本の贈呈は、日本の仏教徒も共々に、世界平和のために努力することを誓うしるしであり、相互の連帯と友情の証なのです。

合掌

1994年7月吉日

カンボジア版トリピタカ（南伝大蔵経）復刻救援委員会

世話人代表　無着　成恭
事務局長　篠原　鋭一

世話人　松永　然道　有馬　実成
伊藤　佳通　渡井　奎一
杉谷　義純　茂田　真澄
前田　利勝　中島　教之
永　六輔

# Acknowledgment

Dear Cambodian friends and respected members of the Cambodian Buddhist community,

It is a matter of great joy that the translation into Cambodian of the Pali Tripitaka has been completed and published. The Tripitaka Commisson of the Buddhist Institute, Phnom Penh, launched the translation project in 1930 and completed the translation, after 39 years of effort, in 1968.

The Cambodian translation of this great work will not only become a cherished treasure of the Cambodian Buddhist community but will also be an important milestone in the history of publication in Cambodia.

The revival and prosperity of Buddhism in Cambodia are the ardent wish of the Japanese Buddhist community, it is in this spirit that we have completed this important project and now present the entire work to the Cambodian Buddhist community, it is a gift not only to the Buddhist community in Cambodia but also to all Cambodian people and all peace-loving people in the world.

Cambodia experienced great tragedies in modern times, and the Cambodian Buddhist community also underwent severe trials and suffered crushing blows during this period. But now a time has come to surmount grief and anger, to forgive, and to start working again for world peace.

This great work is a symbol of the Japanese Buddhist community's resolve to work with our Cambodian brothers and sisters toward world peace and is a testimony to the friendship between our people.

With hands joined in reverence.
July 1994

**TRIPITAKA PUBLISHING SUPPORT COMMITTEE**
Project Manager : The Rev. Seikyo Muchaku
Secretary General : The Rev. Eiitsu Shinohara
Management Team :
The Rev. Zendo Matsunaga The Rev. Jitsujo Arima The Rev. Yoshimichi Ito
The Rev. Keiichi Watai The Rev. Gijun Sugitani The Rev. Shincho Shigeta
The Rev. Risho Maeda The Rev. Kyoshi Nakajima Mr. Rokusuke Ei

# អភិធម្មបិដក

## ធម្មសង្គណិ  បឋមភាគ

៧៨

ព.ស. ២៥០៧

# អភិធម្មបិដកេ

## ធម្មសង្គណិយា បឋមោ ភាគោ

---

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

## មាតិកា

(១) កុសលា ធម្មា អកុសលា ធម្មា អព្យាកតា(១) ធម្មា សុខាយ វេទនាយ សម្បយុត្តា ធម្មា ទុក្ខាយ វេទនាយ សម្បយុត្តា ធម្មា អទុក្ខមសុខាយ វេទនាយ សម្បយុត្តា ធម្មា វិបាកា ធម្មា វិបាកធម្មធម្មា នេវវិបាកនវិបាកធម្មធម្មា ឧបាទិន្នុបាទានិយា ធម្មា អនុបាទិន្នុបាទានិយា ធម្មា អនុបាទិន្នានុបាទានិយា(២) ធម្មា

---

១ ឱ. អវ្យាកតា ។ ២ ឱ. ម. អនុបាទិណ្ណអនុបាទានិយា ។

# អភិធម្មបិដក

# ធម្មសង្គណី បឋមភាគ

*សូមនមស្ការព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះ ។*

## មាតិកា

[១] ពួកធម៌ជាកុសល (១) ពួកធម៌ជាអកុសល (២) ពួកធម៌ជាអព្យាក្រឹត (៣) ពួកធម៌ប្រកបដោយសុខវេទនា (៤) ពួកធម៌ប្រកបដោយទុក្ខវេទនា (៥) ពួកធម៌ប្រកបដោយវេទនាមិនជាទុក្ខ មិនជាសុខ (៦) ពួកធម៌ជាវិបាក (៧) ពួកធម៌មានវិបាកជាប្រក្រតី ពួកធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ពួកធម៌ដែលមានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទាន (៨) ពួកធម៌ដែលមិនមានកម្មប្រកបដោយកិលេសមានតណ្ហាជាដើម កាន់យកហើយ តែជាប្រយោជន៍ដល់ឧបាទាន ពួកធម៌ដែលមិនមានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយ ទាំងមិនជាប្រយោជន៍ ដល់ឧបាទាន

---

១ ធម៌ក្នុងទីនេះ សំដៅយកសភាវៈមិនមែនសត្វមិនមែនជីវិត, កុសល ក្នុងទីនេះ ប្រែថា ធម្មជាតមិនមានទោស១ មានផលជាសុខ១ បានខាងកុសលក្នុងភូមិទាំង ៤ គឺកាមាវចរភូមិ១ រូបាវចរភូមិ១ អរូបាវចរភូមិ១ លោកុត្តរភូមិ១ ។ ២ អកុសល ប្រែថា ធម្មជាតប្រកបដោយទោស១ មានផលជាទុក្ខ១ ។ ៣ អព្យាក្រឹត ព្រះមានបុណ្យមិនសំដែងដោយសភាពជាកុសលនិងអកុសល អព្យាក្រឹតនេះ មានលក្ខណៈឥតផល ។ ៤ សោយអារម្មណ៍ជាទីសប្បាយ ។ ៥ សោយអារម្មណ៍ដ៏លំបាក ។ ៦ ឧបេក្ខាវេទនា ។ ៧ ផលរបស់កុសលនិងអកុសល ។ (ដីកា) ។ ៨ សេចក្តីប្រកាន់មាំ ។

សង្កិលិដ្ឋសង្កិលេសិកា ធម្មា អសង្កិលិដ្ឋសង្កិលេសិកា ធម្មា អសង្កិលិដ្ឋាសង្កិលេសិកា[១] ធម្មា សវិតក្កសវិចារា ធម្មា អវិតក្កវិចារមត្តា ធម្មា អវិតក្កាវិចារា[២] ធម្មា បីតិសហគតា ធម្មា សុខសហគតា ធម្មា ឧបេក្ខាសហគតា ធម្មា ទស្សនេន បហាតព្វា ធម្មា ភាវនាយ បហាតព្វា ធម្មា នេវ ទស្សនេន ន ភាវនាយ បហាតព្វា ធម្មា ទស្សនេន បហាតព្វហេតុកា ធម្មា ភាវនាយ បហាតព្វហេតុកា ធម្មា នេវ ទស្សនេន ន ភាវនាយ បហាតព្វហេតុកា ធម្មា អាចយគាមិនោ ធម្មា អបចយគាមិនោ ធម្មា នេវាចយគាមិនោ នាបចយគាមិនោ[៣] ធម្មា សេក្ខា ធម្មា អសេក្ខា ធម្មា នេវសេក្ខា នាសេក្ខា ធម្មា

---

១ ឱ. ម. អសង្កិលិដ្ឋអសង្កិលេសិកា ។ ២ ឱ. ម. អវិតក្កអវិចារា ។ ៣ ឱ. នេវាចយគាមិនោ ន អបចយគាមិនោ ។ ម. នេវាចយគាមិនាបចយគាមិនោ ។

ពួកធម៌ដែលសៅហ្មង ទាំងគួរដើម្បីដល់នូវសេចក្ដីសៅហ្មង ពួកធម៌ដែលមិនសៅហ្មង តែគួរដើម្បីដល់នូវសេចក្ដីសៅហ្មង ពួកធម៌ដែលមិនសៅ-ហ្មង ទាំងមិនគួរដើម្បីដល់នូវសេចក្ដីសៅហ្មង ពួកធម៌ប្រកបដោយវិតក្កៈ ទាំងប្រកបដោយវិចារៈ(១) ពួកធម៌គ្មានវិតក្កៈ មានត្រឹមតែវិចារៈ ពួកធម៌គ្មានវិតក្កៈទាំងគ្មានវិចារៈ ពួកធម៌ប្រកបដោយបីតិ(២) ពួកធម៌ប្រកបដោយសុខ(៣)ពួកធម៌ប្រកបដោយឧបេក្ខា(៤)ពួកធម៌ដែលត្រូវលះដោយទស្សនៈ(៥) ពួកធម៌ដែលត្រូវលះ ដោយភាវនា (៦) ពួកធម៌ដែលមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ពួកធម៌មានហេតុដែលត្រូវលះដោយទស្សនៈ ពួកធម៌មានហេតុដែលត្រូវលះដោយភាវនា ពួកធម៌មានហេតុដែលមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ពួកធម៌ដល់នូវការសន្សំកពូនឡើងដោយកម្មកិលេស ពួកធម៌មិនដល់នូវការសន្សំកពូនឡើង ពួកធម៌មិនមែនជាដល់នូវការសន្សំកពូនឡើង មិនមែនជាមិនដល់នូវការសន្សំកពូនឡើង ពួកធម៌ជារបស់សេក្ខបុគ្គល ពួកធម៌ជារបស់អសេក្ខ-បុគ្គល ពួកធម៌មិនមែនជារបស់សេក្ខបុគ្គល មិនមែនជារបស់អសេក្ខបុគ្គល

---

១ វិតក្កៈ ប្រែថា ត្រិះរិះ វិចារៈ ប្រែថា ពិចារណា ។ ២ សេចក្ដីត្រេកអរឬឆ្អែតកាយ ឆ្អែតចិត្ត ។ ៣ សេចក្ដីសប្បាយកាយសប្បាយចិត្ត ។ ៤ សេចក្ដីព្រងើយកន្តើយជាកណ្ដាលមិនជាសុខ មិនជាទុក្ខ ។ ៥ ការឃើញ គឺសំដៅយកសោតាបត្តិមគ្គ ។ ៦ ការចំរើន សំដៅយក សកទាគាមិមគ្គ អនាគាមិមគ្គ អរហត្តមគ្គ ។

## អភិធម្មមាតិកា

បរិត្តា ធម្មា មហគ្គតា ធម្មា អប្បមាណា ធម្មា បរិត្តារម្មណា ធម្មា មហគ្គតារម្មណា ធម្មា អប្ប-មាណារម្មណា ធម្មា ហីនា ធម្មា មជ្ឈិមា ធម្មា បណីតា ធម្មា មិច្ឆត្តនិយតា ធម្មា សម្មត្តនិយតា ធម្មា អនិយតា ធម្មា មគ្គារម្មណា ធម្មា មគ្គ-ហេតុកា ធម្មា មគ្គាធិបតិនោ ធម្មា ឧប្បន្នា ធម្មា អនុប្បន្នា ធម្មា ឧប្បាទិនោ ធម្មា អតីតា ធម្មា អនាគតា ធម្មា បច្ចុប្បន្នា ធម្មា អតីតារម្មណា ធម្មា អនាគតារម្មណា ធម្មា បច្ចុប្បន្នារម្មណា ធម្មា អជ្ឈត្តា ធម្មា ពហិទ្ធា ធម្មា អជ្ឈត្តពហិទ្ធា ធម្មា អជ្ឈត្តារម្មណា ធម្មា ពហិទ្ធារម្មណា ធម្មា អជ្ឈត្ត-ពហិទ្ធារម្មណា ធម្មា សនិទស្សនសប្បដិឃា ធម្មា អនិទស្សនសប្បដិឃា ធម្មា អនិទស្សនាប្បដិឃា ធម្មា(១) ។

ពាវីសតិ តិកមាតិកា(២) ។

---

១ ឱ. ម. អនិទស្សនអប្បដិឃា ធម្មា ។ ២ ឱ. តិកំ និដ្ឋិតំ ។ ម. តិកមាតិកា ។

ពួកធម៌មានសភាពតូចឆ្មារ ពួកធម៌ដល់នូវសភាពធំ ពួកធម៌ប្រមាណមិនបាន ពួកធម៌មានអារម្មណ៍តូចឆ្មារ ពួកធម៌មានអារម្មណ៍ដល់នូវសភាពធំ ពួកធម៌មានអារម្មណ៍ប្រមាណមិនបាន ពួកធម៌ថោកទាប ពួកធម៌យ៉ាងកណ្តាល ពួកធម៌ដ៏ឧត្តម ពួកធម៌មានសភាពខុសនិងទៀង ពួកធម៌មានសភាពត្រូវនិងទៀង ពួកធម៌មិនទៀង ពួកធម៌មានមគ្គជាអារម្មណ៍ ពួកធម៌មានមគ្គជាហេតុ ពួកធម៌មានមគ្គជាអធិបតី ពួកធម៌កើតឡើងហើយ ពួកធម៌មិនទាន់កើតឡើង ពួកធម៌ដែលប្រុងនឹងកើតឡើង ពួកធម៌ជាអតីត (កន្លងទៅហើយ) ពួកធម៌ជាអនាគត (មិនទាន់មកដល់) ពួកធម៌ជាបច្ចុប្បន្ន (កើតឡើងចំពោះមុខ) ពួកធម៌មានអារម្មណ៍ជាអតីត ពួកធម៌មានអារម្មណ៍ជាអនាគត ពួកធម៌មានអារម្មណ៍ជាបច្ចុប្បន្ន ពួកធម៌ជាខាងក្នុង ពួកធម៌ជាខាងក្រៅ ពួកធម៌ជាខាងក្នុងនិងខាងក្រៅ ពួកធម៌មានអារម្មណ៍ខាងក្នុង ពួកធម៌មានអារម្មណ៍ខាងក្រៅ ពួកធម៌មានអារម្មណ៍ខាងក្នុង និងខាងក្រៅ ពួកធម៌ប្រកបដោយការឃើញ និងប្រកបដោយការប៉ះពាល់ ពួកធម៌មិនប្រកបដោយការឃើញ តែប្រកបដោយការប៉ះពាល់ ពួកធម៌មិនប្រកបដោយការឃើញមិនប្រកបដោយការប៉ះពាល់ ។

ចប់ តិកមាតិកា ២២ ។

(២) ហេតូ ធម្មា ន ហេតូ ធម្មា សហេតុកា ធម្មា អហេតុកា ធម្មា ហេតុសម្បយុត្តា ធម្មា ហេតុវិប្បយុត្តា ធម្មា ហេតូ ចេវ ធម្មា សហេតុកា ច សហេតុកា ចេវ ធម្មា ន ច ហេតូ ហេតូ ចេវ ធម្មា ហេតុសម្បយុត្តា ច ហេតុសម្បយុត្តា ចេវ ធម្មា ន ច ហេតូ ន[១] ហេតូ ខោ បន ធម្មា សហេតុកាបិ អហេតុកាបិ ។

ហេតុគោច្ឆកំ ។

(៣) សប្បច្ចយា ធម្មា អប្បច្ចយា ធម្មា សង្ខតា ធម្មា អសង្ខតា ធម្មា សនិទស្សនា ធម្មា អនិទស្សនា ធម្មា សប្បដិឃា ធម្មា អប្បដិឃា ធម្មា រូបិនោ ធម្មា អរូបិនោ ធម្មា លោកិយា ធម្មា លោកុត្តរា ធម្មា

---

១ ម. នោ ។

(២) ពួកធម៌ជាហេតុ(១) ពួកធម៌មិនមែនជាហេតុ ពួកធម៌ប្រព្រឹត្តទៅជាមួយនឹងហេតុ ពួកធម៌មិនប្រព្រឹត្តទៅជាមួយនឹងហេតុ ពួកធម៌ប្រកបដោយហេតុ ពួកធម៌ប្រាសចាកហេតុ ពួកធម៌ជាហេតុផង ប្រព្រឹត្តទៅជាមួយនឹងហេតុផង ពួកធម៌គ្រាន់តែប្រព្រឹត្តទៅជាមួយនឹងហេតុ តែមិនមែនជាហេតុ ពួកធម៌ជាហេតុផង ប្រកបដោយហេតុផង ពួកធម៌គ្រាន់តែប្រកបដោយហេតុ តែមិនមែនជាហេតុ ពួកធម៌មិនមែនជាហេតុ តែប្រព្រឹត្តទៅជាមួយនឹងហេតុ ពួកធម៌មិនមែនជាហេតុផង មិនប្រព្រឹត្តទៅជាមួយនឹងហេតុផង ។

ចប់ ពួកហេតុ ។

(៣) ពួកធម៌ប្រកបដោយបច្ច័យ(២) ពួកធម៌មិនមានបច្ច័យ ពួកធម៌មានបច្ច័យតាក់តែង ពួកធម៌ឥតបច្ច័យតាក់តែង ពួកធម៌ប្រកបដោយការឃើញ ពួកធម៌មិនប្រកបដោយការឃើញ ពួកធម៌ប្រកបដោយការប៉ះពាល់ ពួកធម៌មិនប្រកបដោយការប៉ះពាល់ ពួកធម៌មានរូប ពួកធម៌មិនមានរូប ពួកធម៌ជាលោកិយ (៣) ពួកធម៌ជាលោកុត្តរៈ(៤)

---

១ ឫសគល់ ឬថា មេនាំបណ្ដាលឲ្យកើតផល ។ ២ បច្ច័យ ប្រែថា ជាដែនអាស្រ័យហើយប្រព្រឹត្តទៅនៃផល គឺជាហេតុនាំឲ្យកើតផលដូចគ្នានឹងហេតុ ។ ៣ លោកិយ ប្រែថា ប្រព្រឹត្តទៅក្នុងលោក ។ លោក-សត្វ ក្នុងទីនេះ សំដៅយកវដ្តៈ ។ ៤ លោកុត្តរៈ ប្រែថា ផុតចាកលោក ។

កេនចិ វិញ្ញេយ្យា ធម្មា កេនចិ ន វិញ្ញេយ្យា ធម្មា ។

ចូឡន្តរទុកំ ។

(៦) អាសវា ធម្មា នោ អាសវា ធម្មា សាសវា ធម្មា អនាសវា ធម្មា អាសវសម្បយុត្តា ធម្មា អាសវវិប្បយុត្តា ធម្មា អាសវា ចេវ ធម្មា សាសវា ច សាសវា ចេវ ធម្មា នោ ច អាសវា អាសវា ចេវ ធម្មា អាសវសម្បយុត្តា ច អាសវសម្បយុត្តា ចេវ ធម្មា នោ ច អាសវា អាសវវិប្បយុត្តា ខោ បន ធម្មា សាសវាបិ អនាសវាបិ ។

អាសវគោច្ឆកំ ។

ពួកធម៌គួរដឹងច្បាស់ដោយវិញ្ញាណនីមួយ គឺចក្ខុវិញ្ញាណឬសោតវិញ្ញាណជាដើម ពួកធម៌ដែលមិនគួរដឹងច្បាស់ដោយវិញ្ញាណនីមួយ ។

ចប់ ចូឡន្តរទុកៈ ។

[៤] ពួកធម៌ជាអាសវៈ(១) ពួកធម៌មិនមែនជាអាសវៈ ពួកធម៌ប្រព្រឹត្តទៅជាមួយនឹងអាសវៈ ពួកធម៌មិនប្រព្រឹត្តទៅជាមួយនឹងអាសវៈ ពួកធម៌ប្រកបដោយអាសវៈ ពួកធម៌ប្រាសចាកអាសវៈ ពួកធម៌ជាអាសវៈផង ប្រព្រឹត្តទៅជាមួយនឹងអាសវៈផង ពួកធម៌គ្រាន់តែប្រព្រឹត្តទៅជាមួយនឹងអាសវៈ តែមិនមែនជាអាសវៈ ពួកធម៌ជាអាសវៈផង ប្រកបដោយអាសវៈផង ពួកធម៌គ្រាន់តែប្រកបដោយអាសវៈ តែមិនមែនជាអាសវៈ ពួកធម៌ប្រាសចាកអាសវៈ តែប្រព្រឹត្តទៅជាមួយនឹងអាសវៈ ពួកធម៌ប្រាសចាកអាសវៈផង មិនប្រព្រឹត្តទៅជាមួយនឹងអាសវៈផង ។

ចប់ ពួកអាសវៈ ។

---

១ អាសវៈ-សព្ទនេះ ប្រែថា ហូរទៅ គឺហូរទៅតាមចក្ខុទ្វារជាដើម ឬហូរតាមផ្លូវធម៌រហូតដល់គោត្រភូ ហូរតាមឱកាសរហូតដល់ភវគ្គព្រហ្ម មួយទៀត អាសវៈ-សព្ទ ជាឈ្មោះរបស់គ្រឿងត្រាំមានមេរ័យជាដើម អាសវធម៌ដូចគ្នានឹងមេរ័យជាដើមនោះ, មួយទៀត អាសវៈប្រែថា ញុំាងសង្សារទុក្ខវែងឆ្ងាយឲ្យកើតឡើង មួយទៀត អាសវៈ-សព្ទជាឈ្មោះ អសុចិ គ្រឿងស្មោកគ្រោកទាំងពួង, សវៈ-សព្ទ ប្រែថា ហូរទៅ អសុចិ ហូរទៅជាប្រក្រតី ហៅថា អាសវៈ ។

(៥) សញ្ញោជនា ធម្មា នោ សញ្ញោជនា ធម្មា សញ្ញោជនិយា ធម្មា អសញ្ញោជនិយា ធម្មា សញ្ញោជនសម្បយុត្តា ធម្មា សញ្ញោជនវិប្បយុត្តា ធម្មា សញ្ញោជនា ចេវ ធម្មា សញ្ញោជនិយា ច សញ្ញោជនិយា ចេវ ធម្មា នោ ច សញ្ញោជនា សញ្ញោជនា ចេវ ធម្មា សញ្ញោជនសម្បយុត្តា ច សញ្ញោជនសម្បយុត្តា ចេវ ធម្មា នោ ច សញ្ញោជនា សញ្ញោជនវិប្បយុត្តា ខោ បន ធម្មា សញ្ញោជនិយាបិ អសញ្ញោជនិយាបិ ។

សញ្ញោជនគោច្ឆកំ ។

(៦) គន្ថា ធម្មា នោ គន្ថា ធម្មា គន្ថនិយា ធម្មា អគន្ថនិយា ធម្មា គន្ថសម្បយុត្តា ធម្មា គន្ថវិប្បយុត្តា ធម្មា គន្ថា ចេវ ធម្មា គន្ថនិយា ច

(៥) ពួកធម៌ជាសញ្ញោជនៈ (ធម៌ចងសត្វទុកក្នុងវដ្ដៈ) ពួកធម៌មិនមែនជាសញ្ញោជនៈ ពួកធម៌ជាប្រយោជន៍ ឬសមគួរដល់សញ្ញោជនៈ ពួកធម៌មិនមែនជាប្រយោជន៍ ឬមិនសមគួរដល់សញ្ញោជនៈ ពួកធម៌ប្រកបដោយសញ្ញោជនៈ ពួកធម៌ប្រាសចាកសញ្ញោជនៈ ពួកធម៌ជាសញ្ញោជនៈផង ជាប្រយោជន៍ដល់សញ្ញោជនៈផង ពួកធម៌គ្រាន់តែជាប្រយោជន៍ដល់សញ្ញោជនៈ តែមិនមែនជាសញ្ញោជនៈ ពួកធម៌ជាសញ្ញោជនៈផង ប្រកបដោយសញ្ញោជនៈផង ពួកធម៌គ្រាន់តែប្រកបដោយសញ្ញោជនៈ តែមិនមែនជាសញ្ញោជនៈ ពួកធម៌ប្រាសចាកសញ្ញោជនៈតែជាប្រយោជន៍ដល់សញ្ញោជនៈ ពួកធម៌ប្រាសចាកសញ្ញោជនៈ តែជាប្រយោជន៍ដល់សញ្ញោជនៈ ពួកធម៌ប្រាសចាកសញ្ញោជនៈផង មិនជាប្រយោជន៍ដល់សញ្ញោជនៈផង ។

ចប់ ពួកសញ្ញោជនៈ ។

(៦) ពួកធម៌ជាគន្ថៈ (ធម៌ដោតក្រងសត្វទុកក្នុងវដ្ដៈដោយអំណាចចុតិនិងបដិសន្ធិ) ពួកធម៌មិនមែនជាគន្ថៈ ពួកធម៌ដែលគន្ថៈគប្បីដោតក្រង ពួកធម៌ដែលគន្ថៈមិនគប្បីដោតក្រង ពួកធម៌ប្រកបដោយគន្ថៈ ពួកធម៌ប្រាសចាកគន្ថៈ ពួកធម៌ជាគន្ថៈផង ដែលគន្ថៈគប្បីដោតក្រងផង

គន្ថនិយា ចេវ ធម្មា នោ ច គន្ថា គន្ថា ចេវ ធម្មា គន្ថសម្បយុត្តា ច គន្ថសម្បយុត្តា ចេវ ធម្មា នោ ច គន្ថា គន្ថវិប្បយុត្តា ខោ បន ធម្មា គន្ថនិយាបិ អគន្ថនិយាបិ ។

## គន្ថគោច្ឆកំ ។

(៧) ឱឃា ធម្មា នោ ឱឃា ធម្មា ឱឃនិយា ធម្មា អនោឃនិយា ធម្មា ឱឃសម្បយុត្តា ធម្មា ឱឃវិប្បយុត្តា ធម្មា ឱឃា ចេវ ធម្មា ឱឃនិយា ច ឱឃនិយា ចេវ ធម្មា នោ ច ឱឃា ឱឃា ចេវ ធម្មា ឱឃសម្បយុត្តា ច ឱឃសម្បយុត្តា ចេវ ធម្មា នោ ច ឱឃា ឱឃវិប្បយុត្តា ខោ បន ធម្មា ឱឃនិយាបិ អនោឃនិយាបិ ។

## ឱឃគោច្ឆកំ ។

ពួកធម៌ដែលគន្ថៈគប្បីដោតក្រង តែមិនមែនជាគន្ថៈ ពួកធម៌ជាគន្ថៈផង ប្រកបដោយគន្ថៈផង ពួកធម៌គ្រាន់តែប្រកបដោយគន្ថៈ តែមិនមែនជាគន្ថៈ ពួកធម៌ប្រាសចាកគន្ថៈ តែគន្ថៈគប្បីដោតក្រង ពួកធម៌ប្រាសចាកគន្ថៈផង ដែលគន្ថៈមិនគប្បីដោតក្រងផង ។

ចប់ ពួកគន្ថៈ ។

(៧) ពួកធម៌ជាឱឃៈ (ធម៌ញ៉ាំងសត្វឲ្យលង់នៅក្នុងវដ្ដៈ) ពួកធម៌មិនមែនជាឱឃៈ ពួកធម៌ដែលឱឃៈគប្បីប្រព្រឹត្តកន្លង ពួកធម៌ដែលឱឃៈមិនគប្បីប្រព្រឹត្តកន្លង ពួកធម៌ប្រកបដោយឱឃៈ ពួកធម៌ប្រាសចាកឱឃៈ ពួកធម៌ជាឱឃៈផង ដែលឱឃៈគប្បីប្រព្រឹត្តកន្លងផង ពួកធម៌ដែលឱឃៈគប្បីប្រព្រឹត្តកន្លង តែមិនមែនជាឱឃៈ ពួកធម៌ជាឱឃៈផង ប្រកបដោយឱឃៈផង ពួកធម៌គ្រាន់តែប្រកបដោយឱឃៈ តែមិនមែនជាឱឃៈ ពួកធម៌ប្រាសចាកឱឃៈ តែឱឃៈគប្បីប្រព្រឹត្តកន្លង ពួកធម៌ប្រាសចាកឱឃៈផង ឱឃៈមិនគប្បីប្រព្រឹត្តកន្លងផង ។

ចប់ ពួកឱឃៈ ។

(៨) យោគា ធម្មា នោ យោគា ធម្មា យោគនិយា ធម្មា អយោគនិយា ធម្មា យោគសម្បយុត្តា ធម្មា យោគវិប្បយុត្តា ធម្មា យោគា ចេវ ធម្មា យោគនិយា ច យោគនិយា ចេវ ធម្មា នោ ច យោគា យោគា ចេវ ធម្មា យោគសម្បយុត្តា ច យោគសម្បយុត្តា ចេវ ធម្មា នោ ច យោគា យោគវិប្បយុត្តា ខោ បន ធម្មា យោគនិយាបិ អយោគនិយាបិ ។

យោគគោច្ឆកំ ។

(៩) នីវរណា ធម្មា នោ នីវរណា ធម្មា នីវរណិយា ធម្មា អនីវរណិយា ធម្មា នីវរណសម្បយុត្តា ធម្មា នីវរណវិប្បយុត្តា ធម្មា នីវរណា ចេវ ធម្មា នីវរណិយា ច នីវរណិយា ចេវ ធម្មា នោ ច នីវរណា នីវរណា ចេវ ធម្មា នីវរណសម្បយុត្តា ច

(៨) ពួកធម៌ជាយោគៈ (ធម៌ញុំាងសត្វឲ្យជាប់នៅក្នុងវដ្តៈ) ពួកធម៌មិនមែនជាយោគៈ ពួកធម៌ដែលយោគៈគប្បីប្រព្រឹត្តកន្លង ពួកធម៌ដែលយោគៈមិនគប្បីប្រព្រឹត្តកន្លង ពួកធម៌ប្រកបដោយយោគៈ ពួកធម៌ប្រាសចាកយោគៈ ពួកធម៌ជាយោគៈផង ដែលយោគៈគប្បីប្រព្រឹត្តកន្លងផង ពួកធម៌ដែលយោគៈគប្បីប្រព្រឹត្តកន្លង តែមិនមែនជាយោគៈ ពួកធម៌ជាយោគៈផង ប្រកបដោយយោគៈផង ពួកធម៌គ្រាន់តែប្រកបដោយយោគៈ តែមិនមែនជាយោគៈ ពួកធម៌ប្រាសចាកយោគៈ តែយោគៈគប្បីប្រព្រឹត្តកន្លង ពួកធម៌ប្រាសចាកយោគៈផង ដែលយោគៈមិនគប្បីប្រព្រឹត្តកន្លងផង ។

ចប់ ពួកយោគៈ ។

(៩) ពួកធម៌ជានីវរណៈ (ធម៌រួបរឹតចិត្តសត្វ) ពួកធម៌មិនមែនជានីវរណៈ ពួកធម៌ជាប្រយោជន៍ដល់នីវរណៈ ពួកធម៌មិនជាប្រយោជន៍ដល់នីវរណៈ ពួកធម៌ប្រកបដោយនីវរណៈ ពួកធម៌ប្រាសចាកនីវរណៈ ពួកធម៌ជានីវរណៈផង ជាប្រយោជន៍ដល់នីវរណៈផង ពួកធម៌ជាប្រយោជន៍ដល់នីវរណៈ តែមិនមែនជានីវរណៈ ពួកធម៌ជានីវរណៈផង ប្រកបដោយនីវរណៈផង

## អភិធម្មមាតិកា

នីវរណសម្បយុត្តា ចេវ ធម្មា នោ ច នីវរណា នីវរណវិប្បយុត្តា ខោ បន ធម្មា នីវរណិយាបិ អនីវរណិយាបិ ។

### នីវរណគោច្ឆកំ ។

(១០) បរាមាសា ធម្មា នោ បរាមាសា ធម្មា បរាមដ្ឋា ធម្មា អបរាមដ្ឋា ធម្មា បរាមាសសម្បយុត្តា ធម្មា បរាមាសវិប្បយុត្តា ធម្មា បរាមាសា ចេវ ធម្មា បរាមដ្ឋា ច បរាមដ្ឋា ចេវ ធម្មា នោ ច បរាមាសា បរាមាសវិប្បយុត្តា ខោ បន ធម្មា បរាមដ្ឋាបិ អបរាមដ្ឋាបិ ។

### បរាមាសគោច្ឆកំ ។

(១១) សារម្មណា ធម្មា អនារម្មណា ធម្មា ចិត្តា ធម្មា នោ ចិត្តា ធម្មា ចេតសិកា ធម្មា អចេតសិកា ធម្មា ចិត្តសម្បយុត្តា ធម្មា ចិត្តវិប្ប-យុត្តា ធម្មា ចិត្តសំសដ្ឋា ធម្មា ចិត្តវិសំសដ្ឋា ធម្មា

ពួកធម៌ គ្រាន់តែប្រកបដោយនីវរណៈ តែមិនមែនជានីវរណៈ ពួកធម៌ ប្រាសចាកនីវរណៈ តែជាប្រយោជន៍ដល់នីវរណៈ ពួកធម៌ ប្រាសចាកនីវរណៈផង មិនជាប្រយោជន៍ដល់នីវរណៈផង ។

ចប់ ពួកនីវរណៈ ។

(១០) ពួកធម៌ជាបរាមាសៈ (សេចក្តីប្រកាន់ខុស) ពួកធម៌មិនមែនជាបរាមាសៈ ពួកធម៌ដែលបរាមាសៈស្ទាបអង្អែល (ធម៌ដែលជ្រោកជ្រាកដោយបរាមាសៈ) ពួកធម៌ដែលពួកបរាមាសៈមិនបានស្ទាបអង្អែល ពួកធម៌ប្រកបដោយបរាមាសៈ ពួកធម៌ដែលប្រាសចាកបរាមាសៈ ពួកធម៌ជាបរាមាសៈផង ដែលបរាមាសៈស្ទាបអង្អែលផង ពួកធម៌គ្រាន់តែបរាមាសៈស្ទាបអង្អែល តែមិនមែនជាបរាមាសៈ ពួកធម៌ប្រាសចាកបរាមាសៈ តែបរាមាសៈស្ទាបអង្អែល ពួកធម៌ ប្រាសចាកបរាមាសៈផង បរាមាសៈមិនបានស្ទាបអង្អែលផង ។

ចប់ ពួកបរាមាសៈ ។

(១១) ពួកធម៌ ប្រកបដោយអារម្មណ៍ ពួកធម៌ មិនមានអារម្មណ៍ ពួកធម៌ជាចិត្ត ពួកធម៌មិនមែនជាចិត្ត ពួកធម៌ជាចេតសិក ពួកធម៌មិនមែនជាចេតសិក ពួកធម៌ ប្រកបដោយចិត្ត ពួកធម៌ ប្រាសចាកចិត្ត ពួកធម៌ប្រឡូកប្រឡំដោយចិត្ត ពួកធម៌មិនប្រឡូកប្រឡំដោយចិត្ត

ចិត្តសមុដ្ឋានា ធម្មា នោ ចិត្តសមុដ្ឋានា ធម្មា ចិត្តសហភុនោ ធម្មា នោ ចិត្តសហភុនោ ធម្មា ចិត្តានុបរិវត្តិនោ ធម្មា នោ ចិត្តានុបរិវត្តិនោ ធម្មា ចិត្តសំសដ្ឋសមុដ្ឋានា ធម្មា នោ ចិត្តសំសដ្ឋសមុដ្ឋានា ធម្មា ចិត្តសំសដ្ឋសមុដ្ឋានសហភុនោ ធម្មា នោ ចិត្តសំសដ្ឋសមុដ្ឋានសហភុនោ ធម្មា ចិត្តសំសដ្ឋសមុដ្ឋានានុបរិវត្តិនោ ធម្មា នោ ចិត្តសំសដ្ឋសមុដ្ឋានានុបរិវត្តិនោ ធម្មា អជ្ឈត្តិកា ធម្មា ពាហិរា ធម្មា ឧបាទា ធម្មា នោ ឧបាទា ធម្មា ឧបាទិន្នា ធម្មា អនុបាទិន្នា ធម្មា ។

## មហន្តរទុកំ ។

(១២) ឧបាទានា ធម្មា នោ ឧបាទានា ធម្មា ឧបាទានិយា ធម្មា អនុបាទានិយា ធម្មា ឧបាទានសម្បយុត្តា ធម្មា ឧបាទានវិប្បយុត្តា ធម្មា ឧបាទានា ចេវ ធម្មា ឧបាទានិយា ច ឧបាទានិយា ចេវ ធម្មា នោ ច ឧបាទានា ឧបាទានា ចេវ ធម្មា

ពួកធម៌តាំងឡើងដោយចិត្ត ពួកធម៌មិនតាំងឡើងដោយចិត្ត ពួកធម៌កើតជាមួយនឹងចិត្ត ពួកធម៌មិនកើតជាមួយនឹងចិត្ត ពួកធម៌ប្រព្រឹត្តទៅតាមចិត្ត ពួកធម៌មិនប្រព្រឹត្តទៅតាមចិត្ត ពួកធម៌ប្រឡូកប្រឡំតាំងឡើងដោយចិត្ត ពួកធម៌មិនប្រឡូកប្រឡំមិនតាំងឡើងដោយចិត្ត ពួកធម៌ប្រឡូកប្រឡំតាំងឡើងកើតជាមួយនឹងចិត្ត ពួកធម៌មិនប្រឡូកប្រឡំមិនតាំងឡើង មិនកើតជាមួយនឹងចិត្ត ពួកធម៌ប្រឡូកប្រឡំតាំងឡើង ប្រព្រឹត្តទៅតាមចិត្ត ពួកធម៌មិនប្រឡូកប្រឡំ មិនតាំងឡើង មិនប្រព្រឹត្តទៅតាមចិត្ត ពួកធម៌ជាខាងក្នុង ពួកធម៌ជាខាងក្រៅ ពួកធម៌ជាឧបាទា (ឧបាទាយរូប) ពួកធម៌មិនមែនជាឧបាទា ពួកធម៌ ដែលកម្មប្រកបដោយកិលេសមានតណ្ហាជាដើមកាន់យកហើយ ពួកធម៌ ដែលកម្មប្រកបដោយកិលេស មានតណ្ហាជាដើមមិនកាន់យកហើយ ។

ចប់ មហន្តរទុកៈ ។

(១៦) ពួកធម៌ជាឧបាទាន (សេចក្តីប្រកាន់មាំ) ពួកធម៌មិនមែនជាឧបាទាន ពួកធម៌ជាប្រយោជន៍ដល់ឧបាទាន ពួកធម៌មិនជាប្រយោជន៍ដល់ឧបាទាន ពួកធម៌ប្រកបដោយឧបាទាន ពួកធម៌ប្រាសចាកឧបាទាន ពួកធម៌ជាឧបាទានផង ជាប្រយោជន៍ដល់ឧបាទានផង ពួកធម៌គ្រាន់តែជាប្រយោជន៍ដល់ឧបាទាន តែមិនមែនជាឧបាទាន ពួកធម៌ជាឧបាទាន

ឧបាទានសម្បយុត្តា ច ឧបាទានសម្បយុត្តា ចេវ ធម្មា នោ ច ឧបាទានា ឧបាទានវិប្បយុត្តា ខោ បន ធម្មា ឧបាទានិយាបិ អនុបាទានិយាបិ ។

ឧបាទានគោច្ឆកំ ។

(១៣) កិលេសា ធម្មា នោ កិលេសា ធម្មា សង្កិលេសិកា ធម្មា អសង្កិលេសិកា ធម្មា សង្កិលិដ្ឋា ធម្មា អសង្កិលិដ្ឋា ធម្មា កិលេសសម្បយុត្តា ធម្មា កិលេសវិប្បយុត្តា ធម្មា កិលេសា ចេវ ធម្មា សង្កិលេសិកា ច សង្កិលេសិកា ចេវ ធម្មា នោ ច កិលេសា កិលេសា ចេវ ធម្មា សង្កិលិដ្ឋា ច សង្កិលិដ្ឋា ចេវ ធម្មា នោ ច កិលេសា កិលេសា ចេវ ធម្មា កិលេសសម្បយុត្តា ច កិលេសសម្បយុត្តា ចេវ ធម្មា នោ ច កិលេសា កិលេសវិប្បយុត្តា ខោ បន ធម្មា សង្កិលេសិកាបិ អសង្កិលេសិកាបិ ។

កិលេសគោច្ឆកំ ។

ផង ប្រកបដោយឧបាទានផង ពួកធម៌គ្រាន់តែប្រកបដោយឧបាទាន តែមិនមែនជាឧបាទាន ពួកធម៌ប្រាសចាកឧបាទាន តែជាប្រយោជន៍ដល់ឧបាទាន ពួកធម៌ប្រាសចាកឧបាទានផង មិនជាប្រយោជន៍ដល់ឧបាទានផង ។

ចប់ ពួកឧបាទាន ។

(១៣) ពួកធម៌ជាកិលេស (ធម៌សៅហ្មង) ពួកធម៌ មិនមែនជាកិលេស ពួកធម៌គួរដើម្បីដល់នូវសេចក្ដីសៅហ្មង ពួកធម៌មិនគួរដើម្បីដល់នូវសេចក្ដីសៅហ្មង ពួកធម៌ដែលសៅហ្មងហើយ ពួកធម៌ដែលមិនសៅហ្មងហើយ ពួកធម៌ប្រកបដោយកិលេស ពួកធម៌ប្រាសចាកកិលេស ពួកធម៌ជាកិលេសផង គួរដើម្បីដល់នូវសេចក្ដីសៅហ្មងផង ពួកធម៌គ្រាន់តែគួរដើម្បីដល់នូវសេចក្ដីសៅហ្មង តែមិនមែនជាកិលេស ពួកធម៌ជាកិលេសផង សៅហ្មងហើយផង ពួកធម៌គ្រាន់តែសៅហ្មងហើយ តែមិនមែនជាកិលេស ពួកធម៌ជាកិលេសផង ប្រកបដោយកិលេសផង ពួកធម៌ គ្រាន់តែប្រកបដោយកិលេស តែមិនមែនជាកិលេស ពួកធម៌ ប្រាសចាកកិលេស តែគួរដើម្បីដល់នូវសេចក្ដីសៅហ្មង ពួកធម៌ប្រាសចាកកិលេសផង មិនគួរដើម្បីដល់នូវសេចក្ដីសៅហ្មងផង ។

ចប់ ពួកកិលេស ។

(១៤) ទស្សនេន បហាតព្វា ធម្មា ន ទស្សនេន បហាតព្វា ធម្មា ភាវនាយ បហាតព្វា ធម្មា ន ភាវនាយ បហាតព្វា ធម្មា ទស្សនេន បហាតព្វហេតុកា ធម្មា ន ទស្សនេន បហាតព្វហេតុកា ធម្មា ភាវនាយ បហាតព្វហេតុកា ធម្មា ន ភាវនាយ បហាតព្វហេតុកា ធម្មា សវិតក្កា ធម្មា អវិតក្កា ធម្មា សវិចារា ធម្មា អវិចារា ធម្មា សប្បីតិកា ធម្មា អប្បីតិកា ធម្មា បីតិសហគតា ធម្មា ន បីតិសហគតា ធម្មា សុខសហគតា ធម្មា ន សុខសហគតា ធម្មា ឧបេក្ខាសហគតា ធម្មា ន ឧបេក្ខាសហគតា ធម្មា កាមាវចរា ធម្មា ន កាមាវចរា ធម្មា រូបាវចរា ធម្មា ន រូបាវចរា ធម្មា អរូបាវចរា ធម្មា ន អរូបាវចរា ធម្មា បរិយាបន្នា ធម្មា អបរិយាបន្នា ធម្មា និយ្យានិកា ធម្មា

(១៤) ពួកធម៌ដែលគួរលះបង់ដោយទស្សនៈ (សោតាបត្តិមគ្គ) ពួកធម៌ដែលមិនគួរលះបង់ដោយទស្សនៈ ពួកធម៌ដែលគួរលះបង់ដោយភាវនា (មគ្គ ៣ ខាងលើ) ពួកធម៌ ដែលមិនគួរលះបង់ដោយភាវនា ពួកធម៌មានហេតុដែលគួរលះបង់ដោយទស្សនៈ ពួកធម៌មិនមានហេតុដែលគួរលះបង់ដោយទស្សនៈ ពួកធម៌មានហេតុដែលគួរលះបង់ដោយភាវនា ពួកធម៌ មិនមានហេតុដែលគួរលះបង់ដោយភាវនា ពួកធម៌ប្រកបដោយវិតក្កៈ (ការត្រិះរិះ) ពួកធម៌មិនមានវិតក្កៈ ពួកធម៌ប្រកបដោយវិចារៈ (ការពិចារណា) ពួកធម៌មិនមានវិចារៈ ពួកធម៌ប្រព្រឹត្តទៅជាមួយនឹងបីតិ (ការត្រេកអរ) ពួកធម៌មិនមានបីតិ ពួកធម៌ ប្រកបដោយបីតិ ពួកធម៌មិនប្រកបដោយបីតិ ពួកធម៌ប្រកបដោយសុខ ពួកធម៌មិនប្រកបដោយសុខ ពួកធម៌ប្រកបដោយឧបេក្ខា ពួកធម៌មិនប្រកបដោយឧបេក្ខា ពួកធម៌ជាកាមាវចរ (ប្រព្រឹត្តទៅក្នុងកាម) ពួកធម៌មិនមែនជាកាមាវចរ ពួកធម៌ជារូបាវចរ ពួកធម៌មិនមែនជារូបាវចរ (ប្រព្រឹត្តទៅក្នុងរូប) ពួកធម៌ជាអរូបាវចរ (ប្រព្រឹត្តទៅក្នុងអរូប) ពួកធម៌មិនជាអរូបាវចរ ពួកធម៌ជាបរិយាបន្នៈ (រាប់បញ្ចូលក្នុងតេភូមិកវដ្ដៈ) ពួកធម៌ជាអបរិយាបន្នៈ ពួកធម៌ជានិយ្យានិកៈ (ធម៌កាត់នូវវដ្ដមូល ធ្វើព្រះនិព្វានឲ្យជាអារម្មណ៍ ហើយចេញចាកវដ្ដៈ)

អនិយ្យានិកា ធម្មា និយតា ធម្មា អនិយតា ធម្មា សឧត្តរា ធម្មា អនុត្តរា ធម្មា សរណា ធម្មា អរណា ធម្មា ។

បិដ្ឋិទុកំ ។

អភិធម្មមាតិកា ។

---

# សុត្តន្តមាតិកា

(១៨) វិជ្ជាភាគិនោ ធម្មា អវិជ្ជាភាគិនោ ធម្មា វិជ្ជូបមា ធម្មា វជិរូបមា ធម្មា ពាលា ធម្មា បណ្ឌិតា ធម្មា កណ្ហា ធម្មា សុក្កា ធម្មា តបនិយា ធម្មា អតបនិយា ធម្មា អធិវចនា ធម្មា អធិវចនបថា ធម្មា និរុត្តិ ធម្មា និរុត្តិបថា ធម្មា បញ្ញត្តិ ធម្មា

ពួកធម៌មិនមែនជានិយ្យានិកៈ ពួកធម៌ទៀង ពួកធម៌មិនទៀង ពួកធម៌ប្រកបដោយឧត្តរៈ (ការរើឡើងនូវខ្លួន) ពួកធម៌មិនមានឧត្តរៈ ពួកធម៌ប្រកបដោយរណៈ (សត្រូវ) ពួកធម៌មិនមានរណៈ ។

ចប់ បិដ្ឋិទុកៈ ។

ចប់ អភិធម្មមាតិកា ។

---

# សុត្តន្តមាតិកា

(១៩) ពួកធម៌ប្រព្រឹត្តទៅក្នុងចំណែកនៃវិជ្ជា ពួកធម៌ប្រព្រឹត្តទៅក្នុងចំណែកនៃអវិជ្ជា ពួកធម៌ប្រៀបដូចផ្លេកបន្ទោរ(១) ពួកធម៌ប្រៀបដូចពេជ្រ(២) ពួកធម៌ពាល(៣) ពួកធម៌បណ្ឌិត(៤) ពួកធម៌ខ្មៅ(៥) ពួកធម៌ស(៦) ពួកធម៌ដុតកំដៅ(៧) ពួកធម៌មិនដុតកំដៅ ពួកធម៌ជាឈ្មោះ ពួកធម៌ជាគន្លងនៃឈ្មោះ ពួកធម៌ជានិរុត្តិ(៨) ពួកធម៌ជាគន្លងនៃនិរុត្តិ ពួកធម៌ជា

---

១ ធម៌ដែលមានកំឡាំងរស្មីស្លួចស្តើង មិនអាចនឹងកំចាត់ងងឹត គឺកិលេសបាន ។ ២ ធម៌ដែលមានកំឡាំងរស្មីភ្លៀវក្លាអាចនឹងកំចាត់ងងឹត គឺកិលេសបាន ។ ៣ ធម៌តាំងនៅក្នុងមនុស្សពាល ឬ ធ្វើមនុស្សឲ្យទៅជាពាលវិញ ។ ៤ ធម៌តាំងនៅក្នុងបណ្ឌិត ឬ ធ្វើមនុស្សឲ្យទៅជាបណ្ឌិតវិញ ។ ៥ ធម៌ធ្វើចិត្តឲ្យអាប់ឥតរស្មី ។ ៦ ធម៌ធ្វើចិត្តឲ្យមានរស្មីភ្លឺថ្លា ។ ៧ ធម៌ញុំាងសត្វឲ្យក្តៅក្នុងលោកនេះ និងលោកខាងមុខ ។ ៨ ប្រែថា ការពោលដោយមិនសល់ សំដៅយកពាក្យវិគ្គហៈ ឬ វិគ្រោះ អធិប្បាយប្រាប់ហេតុ ប្រាប់ផល ដូចពាក្យថា សភាវៈណាតាក់តែងសត្វ សភាវៈនោះ ហៅថាសង្ខារ ជាដើម ។

បញ្ញត្តិបថា ធម្មា នាមញ្ច រូបញ្ច អវិជ្ជា ច ភវតណ្ហា ច ភវទិដ្ឋិ ច វិភវទិដ្ឋិ ច សស្សតទិដ្ឋិ ច ឧច្ឆេទទិដ្ឋិ ច អន្តវាទិដ្ឋិ ច អនន្តវាទិដ្ឋិ ច បុព្វន្តានុទិដ្ឋិ ច អបរន្តានុទិដ្ឋិ ច អហិរិកញ្ច អនោត្តប្បញ្ច ហិរិ ច ឱត្តប្បញ្ច ទោវចស្សតា ច បាបមិត្តតា ច សោវចស្សតា ច កល្យាណមិត្តតា ច អាបត្តិកុសលតា ច អាបត្តិវុដ្ឋានកុសលតា ច សមាបត្តិកុសលតា ច សមាបត្តិវុដ្ឋានកុសលតា ច ធាតុកុសលតា ច មនសិការកុសលតា ច អាយតនកុសលតា ច បដិច្ចសមុប្បាទកុសលតា ច ឋានកុសលតា ច អដ្ឋានកុសលតា ច អជ្ជវោ ច មទ្ទវោ ច ខន្តិ ច សោរច្ចញ្ច សាខល្យញ្ច

## អភិធម្មបិដក ធម្មសង្គណី

បញ្ញត្តិ ពួកធម៌ជាគន្លងនៃបញ្ញត្តិ នាម(១) និង រូប(២) អវិជ្ជា(៣) និង ភវតណ្ហា(៤) ភវទិដ្ឋិ(៥) និងវិភវទិដ្ឋិ(៦) សស្សតទិដ្ឋិ(៧) និង ឧច្ឆេទទិដ្ឋិ (៨) អន្តវាទិដ្ឋិ(៩) និង អនន្តវាទិដ្ឋិ(១០) បុព្វន្តានុទិដ្ឋិ(១១) និង អបរន្តានុទិដ្ឋិ(១២) សេចក្តីមិនខ្មាសបាប និង សេចក្តីមិនកោតខ្លាចបាប សេចក្តីខ្មាសបាប និងសេចក្តីកោតខ្លាចបាប ភាពនៃបុគ្គលប្រដៅក្រ និងភាពនៃបុគ្គលមានមិត្រអាក្រក់ ភាពនៃបុគ្គលប្រដៅងាយ និងភាពនៃបុគ្គលមានមិត្រល្អ សេចក្តីឈ្លាសក្នុងអាបត្តិ និងសេចក្តីឈ្លាសក្នុងការចេញចាកអាបត្តិ សេចក្តីឈ្លាសក្នុងសមាបត្តិ និងសេចក្តីឈ្លាសក្នុងការចេញចាកសមាបត្តិ សេចក្តីឈ្លាសក្នុងធាតុ និងសេចក្តីឈ្លាសក្នុងការធ្វើទុកក្នុងចិត្ត សេចក្តីឈ្លាសក្នុងអាយតនៈ និងសេចក្តីឈ្លាសក្នុងបដិច្ចសមុប្បាទ សេចក្តីឈ្លាសក្នុងហេតុ និងសេចក្តីឈ្លាសក្នុងការមិនមែនជាហេតុ សេចក្តីត្រង់ និងសេចក្តីទន់ភ្លន់ សេចក្តិអត់សង្កត់ និងសេចក្តីស្ងួត សេចក្តីពក់ពាក់

---

១ ប្រែថា ឈ្មោះ មួយទៀតថា ទន់ទោរ ឬបង្អោនទៅ ។ ២ ប្រែថា វិនាស ឬលំបាក ។ ៣ ប្រែថា មិនដឹងអរិយសច្ចទាំង ៤ ។ ៤ សេចក្តីប្រាថ្នាក្នុងភព ឬ សេចក្តីប្រាថ្នាប្រកបដោយសស្សតទិដ្ឋិ ។ ៥ សេចក្តីយល់ឃើញថាសត្វកើតទៀត ហើយទៀង ។ ៦ សេចក្តីយល់ឃើញថាសត្វមិនកើតទៀត ។ ៧ សេចក្តីយល់ឃើញថា ខ្លួននិងលោកជាសភាវៈទៀង ។ ៨ សេចក្តីយល់ឃើញថា សត្វសូន្យមិនកើតទៀត ។ ៩ សេចក្តីយល់ឃើញថា លោកមានទីបំផុត ។ ១០ សេចក្តីយល់ឃើញថា លោកមិនមានទីបំផុត ។ ១១ សេចក្តីយល់ឃើញតាមចំណែកនៃខន្ធខាងដើម ។ ១២ សេចក្តីយល់ឃើញតាមចំណែកនៃខន្ធខាងចុង ។

បដិសន្ថារោ ច ឥន្ទ្រិយេសុ អគុត្តទ្វារតា ច ភោជនេ អមត្តញ្ញុតា ច ឥន្ទ្រិយេសុ គុត្តទ្វារតា ច ភោជនេ មត្តញ្ញុតា ច មុដ្ឋស្សច្ចញ្ច អសម្បជញ្ញញ្ច សតិ ច សម្បជញ្ញញ្ច បដិសង្ខានពលញ្ច ភាវនាពលញ្ច សមថោ ច វិបស្សនា ច សមថនិមិត្តញ្ច បគ្គាហនិមិត្តញ្ច បគ្គាហោ ច អវិក្ខេបោ ច សីលវិបត្តិ ច ទិដ្ឋិវិបត្តិ ច សីលសម្បទា ច ទិដ្ឋិសម្បទា ច សីលវិសុទ្ធិ ច ទិដ្ឋិវិសុទ្ធិ ច ទិដ្ឋិវិសុទ្ធិ ខោ បន យថាទិដ្ឋិស្ស ច បធានំ សំវេគោ ច សំវេជនិយេសុ ឋានេសុ សំវិគ្គស្ស ច យោនិសោ បធានំ អសន្តុដ្ឋតា ច កុសលេសុ ធម្មេសុ អប្បដិវានិតា ច បធានស្មឹ វិជ្ជា ច វិមុត្តិ ច ខយេ ញាណំ អនុប្បាទេ ញាណន្តិ ។

សុត្តន្តមាតិកា ។

មាតិកា និដ្ឋិតា ។

## សុត្តន្តមាតិកា

និងការស្រុះស្រួលខ្លួន ការមិនរក្សាទ្វារក្នុងឥន្ទ្រិយ និងសេចក្ដីមិនដឹងប្រមាណក្នុងភោជន ការរក្សាទ្វារក្នុងឥន្ទ្រិយ និងសេចក្ដីដឹងប្រមាណក្នុងភោជន សេចក្ដីភ្លេចស្មារតី និងសេចក្ដីមិនដឹងខ្លួន ស្មារតី និងសេចក្ដីដឹងខ្លួន កំឡាំងគឺការពិចារណា និងកំឡាំងភាវនា សមថៈ(១) និងវិបស្សនា(២) និមិត្តរបស់សមថៈ និងនិមិត្តនៃការផ្គងឡើង ការផ្គងឡើង និងសេចក្ដីមិនរាយមាយ វិបត្តិនៃសីល និងវិបត្តិនៃទិដ្ឋិ ការបរិបូណ៌នៃសីល និងការបរិបូណ៌នៃទិដ្ឋិ សេចក្ដីបរិសុទ្ធិនៃសីល និងសេចក្ដីបរិសុទ្ធិនៃទិដ្ឋិ សេចក្ដីបរិសុទ្ធិនៃទិដ្ឋិ និងសេចក្ដីព្យាយាមរបស់បុគ្គលដែលមានទិដ្ឋិសមគួរ សេចក្ដីសង្វេគក្នុងទីដែលគួរសង្វេគទាំងឡាយ និងសេចក្ដីព្យាយាមដោយឧបាយនៃបុគ្គលដែលមានសេចក្ដីសង្វេគ សេចក្ដីមិនសន្ដោសក្នុងកុសលធម៌ទាំងឡាយ និងសេចក្ដីមិនថយក្នុងព្យាយាម វិជ្ជានិងវិមុត្តិ សេចក្ដីដឹងក្នុងធម៌(៣) ជាគ្រឿងអស់ទៅនៃកិលេស និងសេចក្ដីដឹងក្នុងធម៌(៤) ដែលធ្វើកិលេសមិនឲ្យកើតឡើងទៀត ។

ចប់ សុត្តន្តមាតិកា ។

ចប់ មាតិកា ។

---

១ សភាវៈរម្ងាប់នូវធម៌ជាសត្រូវ ។ ២ ធម្មជាតិឃើញដោយអាការផ្សេងៗ ។ ៣ អរិយមគ្គ ។ ៤ អរិយផល ។

# បទភាជនីយំ

(១៦) កតមេ ធម្មា កុសលា ។ យស្មឹ សមយេ កាមាវចរំ កុសលំ ចិត្តំ ឧប្បន្នំ ហោតិ សោមនស្សសហគតំ ញាណសម្បយុត្តំ រូបារម្មណំ វា សទ្ទារម្មណំ វា គន្ធារម្មណំ វា រសារម្មណំ វា ផោដ្ឋព្វារម្មណំ វា ធម្មារម្មណំ វា យំ យំ វា បនារព្ភ តស្មឹ សមយេ ផស្សោ ហោតិ វេទនា ហោតិ សញ្ញា ហោតិ ចេតនា ហោតិ ចិត្តំ ហោតិ វិតក្កោ ហោតិ វិចារោ ហោតិ បីតិ ហោតិ សុខំ ហោតិ ចិត្តស្សេកគ្គតា ហោតិ សទ្ធិន្ទ្រិយំ ហោតិ វីរិយិន្ទ្រិយំ ហោតិ សតិន្ទ្រិយំ ហោតិ សមាធិន្ទ្រិយំ ហោតិ បញ្ញិន្ទ្រិយំ ហោតិ មនិន្ទ្រិយំ ហោតិ សោមនស្សិន្ទ្រិយំ ហោតិ ជីវិតិន្ទ្រិយំ ហោតិ សម្មាទិដ្ឋិ ហោតិ សម្មាសង្កប្បោ ហោតិ សម្មាវាយាមោ ហោតិ សម្មាសតិ ហោតិ សម្មាសមាធិ ហោតិ សទ្ធាពលំ ហោតិ វីរិយពលំ ហោតិ សតិពលំ ហោតិ សមាធិពលំ ហោតិ បញ្ញាពលំ

# បទភាជនីយ

(១៦) ពួកធម៌ជាកុសល ដូចម្តេចខ្លះ ។ ចិត្តជាកាមាវចរ-កុសល ប្រកបដោយសោមនស្ស ប្រកបដោយញាណ មានរូបជាអារម្មណ៍ក្តី មានសំឡេងជាអារម្មណ៍ក្តី មានក្លិនជាអារម្មណ៍ក្តី មានរសជាអារម្មណ៍ក្តី មានផោដ្ឋព្វៈជាអារម្មណ៍ក្តី មានធម៌ជាអារម្មណ៍ក្តី ឬជា ប្រារព្ធតែអារម្មណ៍ណាមួយហើយកើតឡើង ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ វេទនា សញ្ញា ចេតនា ចិត្ត វិតក្កៈ វិចារៈ បីតិ សុខ ឯកគ្គតារបស់ចិត្ត សទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ មនិន្ទ្រិយ សោមនស្សិន្ទ្រិយ ជីវិតិន្ទ្រិយ សម្មាទិដ្ឋិ សម្មាសង្កប្បៈ សម្មាវាយាមៈ សម្មាសតិ សម្មាសមាធិ សទ្ធាពលៈ វីរិយពលៈ សតិពលៈ សមាធិពលៈ បញ្ញាពលៈ

ហោតិ ហិរិពលំ ហោតិ ឱត្តប្បពលំ ហោតិ អលោភោ ហោតិ អទោសោ ហោតិ អមោហោ ហោតិ អនភិជ្ឈា ហោតិ អព្យាបាទោ ហោតិ សម្មាទិដ្ឋិ ហោតិ ហិរិ ហោតិ ឱត្តប្បំ ហោតិ កាយប្បស្សទ្ធិ[១] ហោតិ ចិត្តប្បស្សទ្ធិ[២] ហោតិ កាយលហុតា ហោតិ ចិត្តលហុតា ហោតិ កាយ-មុទុតា ហោតិ ចិត្តមុទុតា ហោតិ កាយកម្មញ្ញតា ហោតិ ចិត្តកម្មញ្ញតា ហោតិ កាយបាគុញ្ញតា ហោតិ ចិត្តបាគុញ្ញតា ហោតិ កាយុជុកតា ហោតិ ចិត្តុជុកតា ហោតិ សតិ ហោតិ សម្បជញ្ញំ ហោតិ សមថោ ហោតិ វិបស្សនា ហោតិ បគ្គាហោ ហោតិ អវិក្ខេបោ ហោតិ យេ វា បន តស្មឹ សមយេ អញ្ញេបិ អត្ថិ បដិច្ចសមុប្បន្នា អរូបិនោ ធម្មា ឥមេ ធម្មា កុសលា ។

(១៧) កតមោ តស្មឹ សមយេ ផស្សោ ហោតិ ។ យោ តស្មឹ សមយេ ផស្សោ ផុសនា សម្ផុសនា សម្ផុសិតត្តំ[៣] អយំ តស្មឹ សមយេ ផស្សោ ហោតិ ។

---

១ ឱ. ម. កាយបស្សទ្ធិ ។ ២ ឱ. ម. ចិត្តបស្សទ្ធិ ។ ៣ ឱ. ម. សំផុសនា សំផុសិតត្តំ ។

ហិរិពលៈ ឱត្តប្បពលៈ អលោភៈ អទោសៈ អមោហៈ អនភិជ្ឈា អព្យាបាទ សម្មាទិដ្ឋិ ហិរិ ឱត្តប្បៈ សេចក្តីស្ងប់កាយ សេចក្តីស្ងប់ចិត្ត សេចក្តីស្រាលកាយ សេចក្តីស្រាលចិត្ត សេចក្តីទន់កាយ សេចក្តីទន់ចិត្ត កាយគួរដល់ការងារ ចិត្តគួរដល់ការងារ សេចក្តីស្ទាត់កាយ សេចក្តីស្ទាត់ចិត្ត សេចក្តីត្រង់កាយ សេចក្តីត្រង់ចិត្ត សតិ សម្បជញ្ញៈ សមថៈ វិបស្សនា សេចក្តីផ្គងឡើង សេចក្តីមិនរាយមាយ កើតមានក្នុងសម័យនោះ ឬថា ពួកអរូបធម៌ដទៃណា ដែលកើតឡើងដោយអាស្រ័យហេតុ ក៏កើតមាន ក្នុងសម័យនោះ នេះពួកធម៌ជាកុសល ។

(១៧) ផស្សៈ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ផស្សៈ ការពាល់ត្រូវ ការប៉ះពាល់ ការទង្គិតទង្គិច ណា ក្នុងសម័យនោះ នេះ ផស្សៈ កើតមានក្នុងសម័យនោះ ។

(១៨) កតមា តស្មឹំ សមយេ វេទនា ហោតិ ។ យំ តស្មឹំ សមយេ តជ្ជាមនោវិញ្ញាណធាតុសម្ផស្សជំ ចេតសិកំ សាតំ ចេតសិកំ សុខំ ចេតោសម្ផស្សជំ សាតំ សុខំ វេទយិតំ ចេតោសម្ផស្សជា សាតា សុខា វេទនា អយំ តស្មឹំ សមយេ វេទនា ហោតិ ។

(១៩) កតមា តស្មឹំ សមយេ សញ្ញា ហោតិ ។ យា តស្មឹំ សមយេ តជ្ជាមនោវិញ្ញាណធាតុសម្ផស្សជា សញ្ញា សញ្ជាននា សញ្ជានិតត្តំ អយំ តស្មឹំ សមយេ សញ្ញា ហោតិ ។

(២០) កតមា តស្មឹំ សមយេ ចេតនា ហោតិ ។ យា តស្មឹំ សមយេ តជ្ជាមនោវិញ្ញាណធាតុសម្ផស្សជា ចេតនា សញ្ចេតនា សញ្ចេតយិតត្តំ អយំ តស្មឹំ សមយេ ចេតនា ហោតិ ។

(១៨) វេទនា កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីឆ្ងាញ់ពិសាប្រព្រឹត្តទៅក្នុងចិត្ត សេចក្តីសុខប្រព្រឹត្តទៅក្នុងចិត្ត ដែលកើតអំពីសម្ផស្សនៃមនោវិញ្ញាណធាតុ ដ៏សមគួរដល់សេចក្តីឆ្ងាញ់ពិសា និងសេចក្តីសុខនោះ ការទទួលអារម្មណ៍ដ៏ឆ្ងាញ់ពិសាជាសុខ ដែលកើតអំពីសម្ផស្សនៃចិត្ត វេទនាដ៏ឆ្ងាញ់ពិសាជាសុខ ដែលកើតអំពីសម្ផស្សនៃចិត្ត ណា ក្នុងសម័យនោះ នេះវេទនា កើតមានក្នុងសម័យនោះ ។

(១៩) សញ្ញា កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សញ្ញា សេចក្តីសំគាល់ ភាពនៃសេចក្តីសំគាល់ ណា ដែលកើតអំពីសម្ផស្សនៃមនោវិញ្ញាណធាតុ ដ៏សមគួរដល់កុសលសញ្ញានោះ ក្នុងសម័យនោះ នេះសញ្ញា កើតមានក្នុងសម័យនោះ ។

(២០) ចេតនា កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ចេតនា សេចក្តីរិះគិត ភាពនៃការត្រិះរិះ ណា ដែលកើតអំពីសម្ផស្សនៃមនោ-វិញ្ញាណធាតុ ដ៏សមគួរដល់កុសលចេតនានោះ ក្នុងសម័យនោះ នេះចេតនា កើតមានក្នុងសម័យនោះ ។

(២១) កតមំ តស្មឹ សមយេ ចិត្តំ ហោតិ ។ យំ តស្មឹ សមយេ ចិត្តំ មនោ មានសំ ហទយំ បណ្ឌរំ មនោ មនាយតនំ មនិន្ទ្រិយំ វិញ្ញាណំ វិញ្ញាណក្ខន្ធោ តជ្ជា មនោវិញ្ញាណធាតុ ឥទំ តស្មឹ សមយេ ចិត្តំ ហោតិ ។

(២២) កតមោ តស្មឹ សមយេ វិតក្កោ ហោតិ ។ យោ តស្មឹ សមយេ តក្កោ វិតក្កោ សង្កប្បោ អប្បនា ព្យប្បនា ចេតសោ អភិនិរោបនា សម្មាសង្កប្បោ អយំ តស្មឹ សមយេ វិតក្កោ ហោតិ ។

(២៣) កតមោ តស្មឹ សមយេ វិចារោ ហោតិ ។ យោ តស្មឹ សមយេ ចារោ វិចារោ អនុវិចារោ ឧបវិចារោ ចិត្តស្ស អនុសន្ធនតា អនុបេក្ខនតា អយំ តស្មឹ សមយេ វិចារោ ហោតិ ។

(៦១) ចិត្ត កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ចិត្ត សេចក្តីដឹងនូវអារម្មណ៍ សេចក្តីប្រាថ្នា ហឫទ័យ ធម្មជាតដ៏ផូរផង់ គឺកវ័ន្តចិត្ត ហៅថាមនោ មនាយតនៈ មនិន្ទ្រិយ វិញ្ញាណ វិញ្ញាណក្ខន្ធ មនោវិញ្ញាណធាតុ ដ៏សមគួរដល់ធម៌មានផស្សៈជាដើមនោះ ណា ក្នុងសម័យនោះ នេះចិត្ត កើតមានក្នុងសម័យនោះ ។

(៦២) វិតក្កៈ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីត្រិះរិះ ការរិះគិត គំរិះ ការពិនិត្យ ការផ្ចង់ ការលើកឡើងនូវចិត្ត គឺសម្មាសង្កប្បៈ ណា ក្នុងសម័យនោះ នេះវិតក្កៈ កើតមានក្នុងសម័យនោះ ។

(៦៣) វិចារៈ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ការត្រួតត្រា ការពិចារណា ការពិនិត្យមើល ការសង្កេតមើល ការផ្គងនូវចិត្ត ការសំឡឹងមើល ណា ក្នុងសម័យនោះ នេះវិចារៈ កើតមានក្នុងសម័យនោះ ។

(២៤) កតមា តស្មឹ សមយេ បីតិ ហោតិ ។ យា តស្មឹ សមយេ បីតិ បាមោជ្ជំ អាមោទនា បមោទនា ហាសោ បហាសោ វិត្តិ ឱទគ្យំ អត្តមនតា ចិត្តស្ស អយំ តស្មឹ សមយេ បីតិ ហោតិ ។

(២៥) កតមំ តស្មឹ សមយេ សុខំ ហោតិ ។ យំ តស្មឹ សមយេ ចេតសិកំ សាតំ ចេតសិកំ សុខំ ចេតោសម្ផស្សជំ សាតំ សុខំ វេទយិតំ ចេតោសម្ផស្សជា សាតា សុខា វេទនា ឥទំ តស្មឹ សមយេ សុខំ ហោតិ ។

(២៦) កតមា តស្មឹ សមយេ ចិត្តស្សេកគ្គតា ហោតិ ។ យា តស្មឹ សមយេ ចិត្តស្ស ឋិតិ សណ្ឋិតិ អវដ្ឋិតិ អវិសាហារោ អវិក្ខេបោ អវិសាហដមានសតា សមថោ សមាធិន្ទ្រិយំ សមាធិពលំ សម្មាសមាធិ អយំ តស្មឹ សមយេ ចិត្តស្សេកគ្គតា ហោតិ ។

កុសលជាកាមាវចរ បទភាជនីយ

(៥៤) បីតិ កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ សេចក្ដីឆ្អែតចិត្ត សេចក្ដីរីករាយ សេចក្ដីសប្បាយ សេចក្ដីស្រួល សេចក្ដីស្រស់ស្រាយ ការញញឹមញញែម ការបាននូវអំណរ ការអណ្ដែតអណ្ដូងសេចក្ដី ត្រេកអររបស់ចិត្ត ណា ក្នុងសម័យនោះ នេះបីតិ កើតមានក្នុងសម័យនោះ ។

(៥៥) សុខ កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ សេចក្ដីឆ្ងាញ់ពិសាប្រព្រឹត្តទៅក្នុងចិត្ត សេចក្ដីសុខប្រព្រឹត្តទៅក្នុងចិត្ត សេចក្ដីទទួលអារម្មណ៍ដ៏ឆ្ងាញ់ពិសាជាសុខ ដែលកើតអំពីផស្សៈរបស់ចិត្ត វេទនាដ៏ឆ្ងាញ់ពិសាជាសុខ ដែលកើតអំពីផស្សៈរបស់ចិត្ត ណា ក្នុងសម័យនោះ នេះសុខ កើតមានក្នុងសម័យនោះ ។

(៥៦) ឯកគ្គតារបស់ចិត្ត កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ ការឋិតនៅរបស់ចិត្ត ការតំកល់នៅនឹង ការតាំងមាំ ការមិនឃ្វេង-ឃ្វាង ការមិនរាយមាយ សភាពចិត្តមិនឃ្វេងឃ្វាង ការស្ងប់ស្ងាប់ គឺសមាធិន្ទ្រិយ សមាធិពលៈ សម្មាសមាធិ ណា ក្នុងសម័យនោះ នេះឯកគ្គតារបស់ចិត្ត កើតមានក្នុងសម័យនោះ ។

(២៧) កតមំ តស្មឹ សមយេ សទ្ធិន្ទ្រិយំ ហោតិ ។ យា តស្មឹ សមយេ សទ្ធា សទ្ទហនា ឱកប្បនា អភិប្បសាទោ សទ្ធា សទ្ធិន្ទ្រិយំ សទ្ធាពលំ ឥទំ តស្មឹ សមយេ សទ្ធិន្ទ្រិយំ ហោតិ ។

(២៨) កតមំ តស្មឹ សមយេ វីរិយិន្ទ្រិយំ ហោតិ ។ យោ តស្មឹ សមយេ ចេតសិកោ វីរិយារម្ភោ និក្កមោ បរក្កមោ ឧយ្យាមោ វាយាមោ ឧស្សាហោ ឧស្សោឡ្ហី(១) ថាមោ ធិតិ អសិថិលបរក្កមតា អនិក្ខិត្តច្ឆន្ទតា(២) អនិក្ខិត្តធុរតា ធុរសម្បគ្គាហោ វីរិយំ វីរិយិន្ទ្រិយំ វីរិយពលំ សម្មាវាយាមោ ឥទំ តស្មឹ សមយេ វីរិយិន្ទ្រិយំ ហោតិ ។

(២៩) កតមំ តស្មឹ សមយេ សតិន្ទ្រិយំ ហោតិ ។ យា តស្មឹ សមយេ សតិ អនុស្សតិ បដិស្សតិ សតិ សរណតា ធារណតា អបិលាបនតា អសម្មុស្សនតា(៣) សតិ សតិន្ទ្រិយំ សតិពលំ សម្មាសតិ ឥទំ តស្មឹ សមយេ សតិន្ទ្រិយំ ហោតិ ។

---

១ ឧ. ឧស្សោឡ្ហី ។ ២ ឧ. ម. អនិក្ខិត្តឆន្ទតា ។ ៣ ឧ. ម. អសំមុស្សនតា ។

(២៧) សទ្ធិន្ទ្រិយ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ជំនឿ សេចក្តីជឿ សេចក្តីជឿស៊ប់ សេចក្តីជ្រះថ្លាខ្លាំង គឺសទ្ធា សទ្ធិន្ទ្រិយ សទ្ធាពលៈ ណា ក្នុងសម័យនោះ នេះសទ្ធិន្ទ្រិយ កើតមានក្នុងសម័យនោះ ។

(២៨) វីរិយិន្ទ្រិយ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ការប្រារព្ធព្យាយាមប្រព្រឹត្តទៅក្នុងចិត្ត សេចក្តីឧហាត សង្ហាត ខិតខំ ព្យាយាម ឧស្សាហ៍ ប្រឹងប្រែង ខ្មីឃ្មាត ខ្នះខ្នែង សេចក្តីសង្ហាត ការមិនធូរថយ ការមិនដាក់ចុះនូវសេចក្តីប៉ុនប៉ង ការមិនដាក់ចុះធុរៈ ការផ្គងធុរៈ គឺវីរិយៈ វីរិយិន្ទ្រិយ វីរិយពលៈ សម្មាវាយាមៈ ណា ក្នុងសម័យនោះ នេះវីរិយិន្ទ្រិយ កើតមានក្នុងសម័យនោះ ។

(២៩) សតិន្ទ្រិយ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីរលឹក សេចក្តីរលឹករឿយៗ សេចក្តីរលឹកចំពោះ ស្មារតី ការនឹកបាន ការចាំបាន ការមិនភាន់ច្រឡំ ការមិនភ្លេចភ្លាំង គឺសតិ សតិន្ទ្រិយ សតិពលៈ សម្មាសតិ ណា ក្នុងសម័យនោះ នេះសតិន្ទ្រិយ កើតមានក្នុងសម័យនោះ ។

កុសលេ កាមាវចរេ បទភាជនីយំ

(៣០) កតមំ តស្មិំ សមយេ សមាធិន្ទ្រិយំ ហោតិ ។ យា តស្មិំ សមយេ ចិត្តស្ស ឋិតិ សណ្ឋិតិ អវដ្ឋិតិ អវិសាហារោ អវិក្ខេបោ អវិសាហដមានសតា សមថោ សមាធិន្ទ្រិយំ សមាធិពលំ សម្មាសមាធិ ឥទំ តស្មិំ សមយេ សមាធិន្ទ្រិយំ ហោតិ ។

(៣១) កតមំ តស្មិំ សមយេ បញ្ញិន្ទ្រិយំ ហោតិ ។ យា តស្មិំ សមយេ បញ្ញា បជាននា វិចយោ បវិចយោ ធម្មវិចយោ សល្លក្ខណា ឧបលក្ខណា បច្ចុបលក្ខណា បណ្ឌិច្ចំ កោសល្លំ នេបុញ្ញំ វេភព្យា ចិន្តា ឧបបរិក្ខា ភូរី មេធា បរិណាយិកា វិបស្សនា សម្បជញ្ញំ បតោទោ បញ្ញា បញ្ញិន្ទ្រិយំ បញ្ញាពលំ បញ្ញាសត្ថំ បញ្ញាបាសាទោ បញ្ញាអាលោកោ បញ្ញាឱភាសោ បញ្ញាបជ្ជោតោ បញ្ញារតនំ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ ឥទំ តស្មិំ សមយេ បញ្ញិន្ទ្រិយំ ហោតិ ។

កុសលជាកាមាវចរ បទភាជនីយ

(៣០) សមាធិន្ទ្រិយ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ការឋិតនៅរបស់ចិត្ត ការតំកល់នៅនឹង ការតាំងនៅស៊ប់ ការមិនឃ្លើងឃ្លោង ការមិនរាយមាយ សភាពនៃចិត្តមិនឃ្លើងឃ្លោង ការស្ងប់រម្ងាប់ គឺសមាធិន្ទ្រិយ សមាធិពលៈ សម្មាសមាធិ ណា ក្នុងសម័យនោះ នេះសមាធិន្ទ្រិយ កើតមានក្នុងសម័យនោះ ។

(៣១) បញ្ញិន្ទ្រិយ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ បញ្ញា សេចក្តីដឹងសព្វ សេចក្តីពិចារណា សេចក្តីជ្រើសរើស សេចក្តីពិចារណាធម៌ ការកំណត់ ការកត់សំគាល់ សេចក្តីកត់ត្រា ភាពនៃបណ្ឌិត ភាពនៃអ្នកឈ្លាស ភាពនៃបុគ្គលមានសេចក្តីជ្រះស្អាត ភាពនៃបុគ្គលមានសេចក្តីភ្លឺច្បាស់ សេចក្តីគិត សេចក្តីយល់ ធម្មជាតិដូចផែនដី ធម្មជាតិកំចាត់កិលេស ធម្មជាតិណែនាំ ធម្មជាតិឃើញច្បាស់ សេចក្តីដឹងល្អ សភាពដូចជាជន្លួញគឺបញ្ញា បញ្ញិន្ទ្រិយ បញ្ញាពលៈ គ្រឿងសាស្ត្រាគឺបញ្ញា ប្រាសាទគឺបញ្ញា ពន្លឺគឺបញ្ញា ឱភាសគឺបញ្ញា គ្រឿងឆ្លុះគឺបញ្ញា រតនៈគឺបញ្ញា អមោហៈ ធម្មវិចយៈ សម្មាទិដ្ឋិ ណា ក្នុងសម័យនោះ នេះបញ្ញិន្ទ្រិយ កើតមានក្នុងសម័យនោះ ។

(៣២) កតមំ តស្មឹ សមយេ មនិន្ទ្រិយំ ហោតិ ។ យំ តស្មឹ សមយេ ចិត្តំ មនោ មានសំ ហទយំ បណ្ឌរំ មនោ មនាយតនំ មនិន្ទ្រិយំ វិញ្ញាណំ វិញ្ញាណក្ខន្ធោ តជ្ជា មនោវិញ្ញាណធាតុ ឥទំ តស្មឹ សមយេ មនិន្ទ្រិយំ ហោតិ ។

(៣៣) កតមំ តស្មឹ សមយេ សោមនស្សិន្ទ្រិយំ ហោតិ ។ យំ តស្មឹ សមយេ ចេតសិកំ សាតំ ចេតសិកំ សុខំ ចេតោសម្ផស្សជំ សាតំ សុខំ វេទយិតំ ចេតោសម្ផស្សជា សាតា សុខា វេទនា ឥទំ តស្មឹ សមយេ សោមនស្សិន្ទ្រិយំ ហោតិ ។

(៣៤) កតមំ តស្មឹ សមយេ ជីវិតិន្ទ្រិយំ ហោតិ ។ យោ តេសំ អរូបីនំ ធម្មានំ អាយុ ឋិតិ យបនា យាបនា ឥរិយនា វត្តនា បាលនា ជីវិតំ ជីវិតិន្ទ្រិយំ ឥទំ តស្មឹ សមយេ ជីវិតិន្ទ្រិយំ ហោតិ ។

## អភិធម្មបិដក ធម្មសង្គណី

(៣២) មនិន្ទ្រិយ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ចិត្ត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ហឫទ័យ ធម្មជាតដ៏ផូរផង់ ភវង្គចិត្ត ហៅថាមនោ មនាយតនៈ មនិន្ទ្រិយ វិញ្ញាណ វិញ្ញាណក្ខន្ធ មនោវិញ្ញាណធាតុ ដ៏សមគួរដល់ធម៌មានផស្សៈជាដើមនោះ ណា ក្នុងសម័យនោះ នេះមនិន្ទ្រិយ កើតមានក្នុងសម័យនោះ ។

(៣៣) សោមនស្សិន្ទ្រិយ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីឆ្ងាញ់ពិសាប្រព្រឹត្តទៅក្នុងចិត្ត សេចក្តីសុខប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍ដ៏ឆ្ងាញ់ពិសាជាសុខ ដែលកើតអំពីផស្សៈនៃចិត្ត វេទនាដ៏ឆ្ងាញ់ពិសាជាសុខ ដែលកើតឡើងអំពីផស្សៈនៃចិត្ត ណា ក្នុងសម័យនោះ នេះសោមនស្សិន្ទ្រិយ កើតមានក្នុងសម័យនោះ ។

(៣៤) ជីវិតិន្ទ្រិយ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ អាយុ ការឋិតនៅ ការយឺននៅ ការរស់នៅ ការរំកិលទៅ ការប្រព្រឹត្តទៅ ការរក្សានៃអរូបធម៌ទាំងនោះ គឺជីវិត ជីវិតិន្ទ្រិយ ណា ក្នុងសម័យនោះ នេះជីវិតិន្ទ្រិយ កើតមានក្នុងសម័យនោះ ។

(៣៥) កតមា តស្មឹ សមយេ សម្មាទិដ្ឋិ ហោតិ ។ យា តស្មឹ សមយេ បញ្ញា បជាននា វិចយោ បវិចយោ ធម្មវិចយោ សល្លក្ខណា ឧបលក្ខណា បច្ចុបលក្ខណា បណ្ឌិច្ចំ កោសល្លំ នេបុញ្ញំ វេភព្យា ចិន្តា ឧបបរិក្ខា ភូរី មេធា បរិណាយិកា វិបស្សនា សម្បជញ្ញំ បតោទោ បញ្ញា បញ្ញិន្ទ្រិយំ បញ្ញាពលំ បញ្ញាសត្ថំ បញ្ញាបាសាទោ បញ្ញាអាលោកោ បញ្ញាឱភាសោ បញ្ញាបជ្ជោតោ បញ្ញារតនំ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ អយំ តស្មឹ សមយេ សម្មាទិដ្ឋិ ហោតិ ។

(៣៦) កតមោ តស្មឹ សមយេ សម្មាសង្កប្បោ ហោតិ ។ យោ តស្មឹ សមយេ តក្កោ វិតក្កោ សង្កប្បោ អប្បនា ព្យប្បនា ចេតសោ អភិនិរោបនា សម្មាសង្កប្បោ អយំ តស្មឹ សមយេ សម្មាសង្កប្បោ ហោតិ ។

កុសលជាកាមាវចរ បទភាជនីយ

(៣៥) សម្មាទិដ្ឋិ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ បញ្ញា ការដឹងសព្វ ការពិចារណា ការជ្រើសរើស ការពិចារណាធម៌ ការកំណត់ ការកត់សំគាល់ ការកត់ត្រា ភាពនៃបណ្ឌិត ភាពនៃអ្នកឈ្លាស ភាពនៃអ្នកមានសេចក្តីជ្រះស្អាត ភាពនៃអ្នកមានសេចក្តីច្បាស់ សេចក្តីគិត សេចក្តីយល់ ធម្មជាតិដូចផែនដី ធម្មជាតិកំចាត់កិលេស ធម្មជាតិណែនាំ ធម្មជាតិឃើញច្បាស់ សេចក្តីដឹងល្អ សភាពដូចជាជន្លួញ គឺបញ្ញា បញ្ញិន្ទ្រិយ បញ្ញាពលៈ សស្ត្រាគឺបញ្ញា ប្រាសាទគឺបញ្ញា ពន្លឺគឺបញ្ញា ឱភាសគឺបញ្ញា គ្រឿងផ្លុះគឺបញ្ញា រតនៈគឺបញ្ញា អមោហៈ ធម្មវិចយៈ សម្មាទិដ្ឋិ ណា ក្នុងសម័យនោះ នេះសម្មាទិដ្ឋិ កើតមានក្នុងសម័យនោះ ។

(៣៦) សម្មាសង្កប្បៈ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីត្រិះរិះ ការរិះគិត តំរិះ ការរំពឹង ការជញ្ជឹង ការលើកឡើងនូវចិត្ត គឺសម្មាសង្កប្បៈ ណា ក្នុងសម័យនោះ នេះសម្មាសង្កប្បៈ កើតមានក្នុងសម័យនោះ ។

(៣៧) កតមោ តស្មឹ សមយេ សម្មាវាយាមោ ហោតិ ។ យោ តស្មឹ សមយេ ចេតសិកោ វីរិយារម្ភោ និក្កមោ បរក្កមោ ឧយ្យាមោ វាយាមោ ឧស្សាហោ ឧស្សោឡ្ហី ថាមោ ធិតិ អសិថិលបរក្កមតា អនិក្ខិត្តច្ឆន្ទតា អនិក្ខិត្តធុរតា ធុរសម្បគ្គាហោ វីរិយំ វីរិយិន្ទ្រិយំ វីរិយពលំ សម្មាវាយាមោ អយំ តស្មឹ សមយេ សម្មាវាយាមោ ហោតិ ។

(៣៨) កតមា តស្មឹ សមយេ សម្មាសតិ ហោតិ ។ យា តស្មឹ សមយេ សតិ អនុស្សតិ បដិស្សតិ សតិ សរណតា ធារណតា អបិលាបនតា អសម្មុសនតា សតិ សតិន្ទ្រិយំ សតិពលំ សម្មាសតិ អយំ តស្មឹ សមយេ សម្មាសតិ ហោតិ ។

(៣៩) កតមោ តស្មឹ សមយេ សម្មាសមាធិ ហោតិ ។ យា តស្មឹ សមយេ ចិត្តស្ស ឋិតិ សណ្ឋិតិ អវដ្ឋិតិ អវិសាហារោ អវិក្ខេបោ អវិសាហដមានសតា សមថោ សមាធិន្ទ្រិយំ សមាធិពលំ សម្មាសមាធិ អយំ តស្មឹ សមយេ សម្មាសមាធិ ហោតិ ។

(៣៧) សម្មាវាយាមៈ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ការប្រារព្ធព្យាយាមប្រព្រឹត្តទៅក្នុងចិត្ត សេចក្តីឧហាត សង្វាត ខិតខំព្យាយាម ឧស្សាហ៍ ប្រឹងប្រែង ខ្មីឃ្មាត ខ្នះខ្នែង សេចក្តីសង្វាតមិនធូរថយ ការមិនដាក់ចុះនូវសេចក្តីប៉ុនប៉ង ការមិនដាក់ចុះនូវធុរៈ ការផ្គងធុរៈ គឺវិរិយៈ វិរិយិន្ទ្រិយ វិរិយពលៈ សម្មាវាយាមៈ ណា ក្នុងសម័យនោះ នេះសម្មាវាយាមៈ កើតមានក្នុងសម័យនោះ ។

(៣៨) សម្មាសតិ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីរលឹក សេចក្តីរលឹករឿយៗ សេចក្តីរលឹកចំពោះ ស្មារតី ការនឹកបាន ការចាំបាន ការមិនភាន់ច្រឡំ ការមិនភ្លេចភ្លាំង គឺសតិ សតិន្ទ្រិយ សតិពលៈ សម្មាសតិ ណា ក្នុងសម័យនោះ នេះសម្មាសតិ កើតមានក្នុងសម័យនោះ ។

(៣៩) សម្មាសមាធិ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ការឋិតនៅ ការតំកល់នៅនឹង ការតាំងមាំ ការមិនឃ្វេងឃ្វាង ការមិនរាយមាយ របស់ចិត្ត សភាពនៃចិត្តមិនឃ្វេងឃ្វាង ការស្ងប់រម្ងាប់ចិត្ត គឺសមាធិ សមាធិន្ទ្រិយ សមាធិពលៈ សម្មាសមាធិ ណា ក្នុងសម័យនោះ នេះសម្មាសមាធិ កើតមានក្នុងសម័យនោះ ។

(២០) កតមំ តស្មឹ សមយេ សទ្ធាពលំ ហោតិ ។ យា តស្មឹ សមយេ សទ្ធា សទ្ទហនា ឱកប្បនា អភិប្បសាទោ សទ្ធា សទ្ធិន្ទ្រិយំ សទ្ធាពលំ ឥទំ តស្មឹ សមយេ សទ្ធាពលំ ហោតិ ។

(២១) កតមំ តស្មឹ សមយេ វីរិយពលំ ហោតិ ។ យោ តស្មឹ សមយេ ចេតសិកោ វីរិយារម្ភោ និក្កមោ បរក្កមោ ឧយ្យាមោ វាយាមោ ឧស្សាហោ ឧស្សោឡ្ហី ថាមោ ធិតិ អសិថិលបរក្កមតា អនិក្ខិត្តច្ឆន្ទតា អនិក្ខិត្តធុរតា ធុរសម្បគ្គាហោ វីរិយំ វីរិយិន្ទ្រិយំ វីរិយពលំ សម្មាវាយាមោ ឥទំ តស្មឹ សមយេ វីរិយពលំ ហោតិ ។

(២២) កតមំ តស្មឹ សមយេ សតិពលំ ហោតិ ។ យា តស្មឹ សមយេ សតិ អនុស្សតិ បដិស្សតិ សតិ សរណតា ធារណតា អបិលាបនតា អសម្មុស្សនតា សតិ សតិន្ទ្រិយំ សតិពលំ សម្មាសតិ ឥទំ តស្មឹ សមយេ សតិពលំ ហោតិ ។

## កុសលជាកាមាវចរ បទភាជនីយ

(៤០) សទ្ធាពលៈ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ជំនឿ សេចក្តីជឿ សេចក្តីជឿស៊ប់ សេចក្តីជ្រះថ្លាខ្លាំង គឺសទ្ធា សទ្ធិន្ទ្រិយ សទ្ធាពលៈ ណា ក្នុងសម័យនោះ នេះសទ្ធាពលៈ កើតមានក្នុងសម័យនោះ ។

(៤១) វីរិយពលៈ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ការប្រារព្ធព្យាយាមប្រព្រឹត្តទៅក្នុងចិត្ត សេចក្តីឧហាត សង្វាត ខិតខំ ព្យាយាម ឧស្សាហ៍ ប្រឹងប្រែង ខ្មីឃ្មាត ខ្នះខ្នែង សេចក្តីសង្វាត ការមិនធូរថយ ការមិនដាក់ចុះនូវសេចក្តីប៉ុនប៉ង ការមិនដាក់ធុរៈ ការផ្គងធុរៈ គឺវីរិយៈ វីរិយិន្ទ្រិយ វីរិយពលៈ សម្មាវាយាមៈ ណា ក្នុងសម័យនោះ នេះវីរិយពលៈ កើតមានក្នុងសម័យនោះ ។

(៤២) សតិពលៈ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីរលឹក សេចក្តីរលឹករឿយ ៗ សេចក្តីរលឹកចំពោះ ស្មារតី ការនឹកបាន ការចាំបាន ការមិនភាន់ច្រឡំ ការមិនភ្លេចភ្លាំង គឺសតិ សតិន្ទ្រិយ សតិពលៈ សម្មាសតិ ណា ក្នុងសម័យនោះ នេះសតិពលៈ កើតមានក្នុងសម័យនោះ ។

(៤៣) កតមំ តស្មឹ សមយេ សមាធិពលំ ហោតិ ។ យា តស្មឹ សមយេ ចិត្តស្ស ឋិតិ សណ្ឋិតិ អវដ្ឋិតិ អវិសាហារោ អវិក្ខេបោ អវិសាហដមានសតា សមថោ សមាធិន្ទ្រិយំ សមាធិពលំ សម្មាសមាធិ ឥទំ តស្មឹ សមយេ សមាធិពលំ ហោតិ ។

(៤៤) កតមំ តស្មឹ សមយេ បញ្ញាពលំ ហោតិ ។ យា តស្មឹ សមយេ បញ្ញា បជាននា វិចយោ បវិចយោ ធម្មវិចយោ សល្លក្ខណា ឧបលក្ខណា បច្ចុបលក្ខណា បណ្ឌិច្ចំ កោសល្លំ នេបុញ្ញំ វេភព្យា ចិន្តា ឧបបរិក្ខា ភូរី មេធា បរិណាយិកា វិបស្សនា សម្បជញ្ញំ បតោទោ បញ្ញា បញ្ញិន្ទ្រិយំ បញ្ញាពលំ បញ្ញាសត្ថំ បញ្ញាបាសាទោ បញ្ញាអាលោកោ បញ្ញាឱភាសោ បញ្ញាបជ្ជោតោ បញ្ញារតនំ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ ឥទំ តស្មឹ សមយេ បញ្ញាពលំ ហោតិ ។

(៤៣) សមាធិពលៈ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ការឋិតនៅ ការតាំងនៅនឹង ការតាំងនៅស៊ប់ ការមិនឃ្លេងឃ្លោង ការមិនរាយមាយ របស់ចិត្ត សភាពនៃចិត្តមិនឃ្លេងឃ្លោង ការស្ងប់រម្ងាប់ចិត្ត គឺសមាធិន្ទ្រិយ សមាធិពលៈ សម្មាសមាធិ ណា ក្នុងសម័យនោះ នេះសមាធិពលៈ កើតមានក្នុងសម័យនោះ ។

(៤៤) បញ្ញាពលៈ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ បញ្ញា សេចក្តីដឹងសព្វ សេចក្តីពិចារណា សេចក្តីជ្រើសរើស សេចក្តីពិចារណាធម៌ ការកំណត់ ការកត់សំគាល់ សេចក្តីកត់ត្រា ភាពនៃបណ្ឌិត ភាពនៃអ្នកឈ្លាស ភាពនៃបុគ្គលមានសេចក្តីជ្រះស្អាត ភាពនៃបុគ្គលមានសេចក្តីភ្លឺច្បាស់ សេចក្តីគិត សេចក្តីយល់ ធម្មជាតិដូចជាផែនដី ធម្មជាតិកំចាត់កិលេស ធម្មជាតិណែនាំ ធម្មជាតិឃើញច្បាស់ សេចក្តីដឹងល្អ សភាពដូចជាជន្លួញគឺបញ្ញា បញ្ញិន្ទ្រិយ បញ្ញាពលៈ សស្ត្រាគឺបញ្ញា ប្រាសាទគឺបញ្ញា ពន្លឺគឺបញ្ញា ឱភាសគឺបញ្ញា គ្រឿងឆ្លុះគឺបញ្ញា រតនៈគឺបញ្ញា អមោហៈ ធម្មវិចយៈ សម្មាទិដ្ឋិ ណា ក្នុងសម័យនោះ នេះបញ្ញាពលៈ កើតមានក្នុងសម័យនោះ ។

(៤៥) កតមំ តស្មិំ សមយេ ហិរិពលំ ហោតិ ។ យំ តស្មិំ សមយេ ហិរិយតិ ហិរិយិតព្វេន ហិរិយតិ បាបកានំ អកុសលានំ ធម្មានំ សមាបត្តិយា ឥទំ តស្មិំ សមយេ ហិរិពលំ ហោតិ ។

(៤៦) កតមំ តស្មិំ សមយេ ឱត្តប្បពលំ ហោតិ ។ យំ តស្មិំ សមយេ ឱត្តប្បតិ ឱត្តប្បិតព្វេន ឱត្តប្បតិ បាបកានំ អកុសលានំ ធម្មានំ សមាបត្តិយា ឥទំ តស្មិំ សមយេ ឱត្តប្បពលំ ហោតិ ។

(៤៧) កតមោ តស្មិំ សមយេ អលោភោ ហោតិ ។ យោ តស្មិំ សមយេ អលោភោ អលុព្ភនា អលុព្ភិតត្តំ អសារាគោ អសារជ្ជនា អសារជ្ជិតត្តំ អនភិជ្ឈា អលោភោ កុសលមូលំ អយំ តស្មិំ សមយេ អលោភោ ហោតិ ។

(៤៥) ហិរិពលៈ កើតមានក្នុងសម័យនោះ តើដូចម្ដេច ៗ ត្រង់ដែលបុគ្គលខ្មាស ដោយវត្ថុដែលគួរខ្មាស ខ្មាសដោយការជួបប្រទះនឹងអកុសលធម៌ដ៏លាមក ក្នុងសម័យនោះ នេះហិរិពលៈ កើតមានក្នុងសម័យនោះ ៗ

(៤៦) ឱត្តប្បពលៈ កើតមានក្នុងសម័យនោះ តើដូចម្ដេច ៗ ត្រង់ដែលបុគ្គលតក់ស្លុត ដោយវត្ថុដែលគួរតក់ស្លុត តក់ស្លុតដោយការជួបប្រទះនឹងអកុសលធម៌ដ៏លាមក ក្នុងសម័យនោះ នេះឱត្តប្បពលៈ កើតមានក្នុងសម័យនោះ ៗ

(៤៧) អលោភៈ កើតមានក្នុងសម័យនោះ តើដូចម្ដេច ៗ ការមិនចង់បាន ការមិនជាប់ចំពាក់ សេចក្ដីមិនជាប់ចំពាក់ ការមិនត្រេកអរខ្លាំង ការមិនត្រេកត្រអាល សេចក្ដីមិនត្រេកត្រអាល ការមិនសំឡឹងចំពោះ គឺអលោភៈ ជាកុសលមូល ណា ក្នុងសម័យនោះ នេះអលោភៈ កើតមានក្នុងសម័យនោះ ៗ

(៤៨) កតមោ តស្មឹ សមយេ អទោសោ ហោតិ ។ យោ តស្មឹ សមយេ អទោសោ អទុស្សនា[1] អទុស្សិតត្តំ អព្យាបាទោ អព្យាបជ្ជោ អទោសោ កុសលមូលំ អយំ តស្មឹ សមយេ អទោសោ ហោតិ ។

(៤៩) កតមោ តស្មឹ សមយេ អមោហោ ហោតិ ។ យា តស្មឹ សមយេ បញ្ញា បជាននា វិចយោ បវិចយោ ធម្មវិចយោ សល្លក្ខណា ឧបលក្ខណា បច្ចុបលក្ខណា បណ្ឌិច្ចំ កោសល្លំ នេបុញ្ញំ វេភព្យា ចិន្តា ឧបបរិក្ខា ភូរី មេធា បរិណាយិកា វិបស្សនា សម្បជញ្ញំ បតោទោ បញ្ញា បញ្ញិន្ទ្រិយំ បញ្ញាពលំ បញ្ញាសត្ថំ បញ្ញាបាសាទោ បញ្ញាអាលោកោ បញ្ញាឱភាសោ បញ្ញាបជ្ជោតោ បញ្ញារតនំ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ អមោហោ កុសលមូលំ អយំ តស្មឹ សមយេ អមោហោ ហោតិ ។

---

១ ឱ. ម. អទុស្សនា ។

អភិធម្មបិដក ធម្មសង្គណី

(៤៨) អទោសៈ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីមិនខឹង ការមិនប្រទូស្ត សេចក្តីមិនប្រទូស្ត ការមិនព្យាបាទ សេចក្តីមិនព្យាបាទ គឺអទោសៈ ជាកុសលមូល ណា ក្នុងសម័យនោះ នេះអទោសៈ កើតមានក្នុងសម័យនោះ ។

(៤៩) អមោហៈ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ បញ្ញា សេចក្តីដឹងសព្វ សេចក្តីពិចារណា សេចក្តីជ្រើសរើស សេចក្តីពិចារណាធម៌ ការកំណត់ ការសំគាល់ សេចក្តីកត់ត្រា ភាពនៃបណ្ឌិត ភាពនៃអ្នកឈ្លាស ភាពនៃបុគ្គលមានសេចក្តីជ្រះស្អាត ភាពនៃបុគ្គលមានសេចក្តីក្តីច្បាស់ សេចក្តីគិត សេចក្តីយល់ ធម្មជាតិដូចផែនដី ធម្មជាតិកំចាត់កិលេស ធម្មជាតិណែនាំ ធម្មជាតិឃើញច្បាស់ សេចក្តីដឹងល្អ សភាពដូចជាជន្លួញ គឺបញ្ញា បញ្ញិន្ទ្រិយ បញ្ញាពលៈ គ្រឿងសស្ត្រាគឺបញ្ញា ប្រាសាទគឺបញ្ញា ពន្លឺគឺបញ្ញា ឱភាសគឺបញ្ញា គ្រឿងថ្ងះគឺបញ្ញា រតនៈគឺបញ្ញា អមោហៈ ធម្មវិចយៈ សម្មាទិដ្ឋិ គឺអមោហៈ ជាកុសលមូល ណា ក្នុងសម័យនោះ នេះអមោហៈ កើតមានក្នុងសម័យនោះ ។

(៤០) កតមា តស្មឹ សមយេ អនភិជ្ឈា ហោតិ ។ យោ តស្មឹ សមយេ អលោភោ អលុព្ភនា អលុព្ភិតត្តំ អសារាគោ អសារជ្ជនា អសារជ្ជិតត្តំ អនភិជ្ឈា អលោភោ កុសលមូលំ អយំ តស្មឹ សមយេ អនភិជ្ឈា ហោតិ ។

(៤១) កតមោ តស្មឹ សមយេ អព្យាបាទោ ហោតិ ។ យោ តស្មឹ សមយេ អទោសោ អទុស្សនា អទុស្សិតត្តំ អព្យាបាទោ អព្យាបជ្ជោ អទោសោ កុសលមូលំ អយំ តស្មឹ សមយេ អព្យាបាទោ ហោតិ ។

(៤២) កតមា តស្មឹ សមយេ សម្មាទិដ្ឋិ ហោតិ ។ យា តស្មឹ សមយេ បញ្ញា បជាននា វិចយោ បវិចយោ ធម្មវិចយោ សល្លក្ខណា ឧបលក្ខណា បច្ចុបលក្ខណា បណ្ឌិច្ចំ កោសល្លំ នេបុញ្ញំ វេភព្យា ចិន្តា ឧបបរិក្ខា ភូរី

កុសលចិត្តកាមាវចរ បឋមភាជនីយ

(៩០) អនភិជ្ឈា កើតមានក្នុងសម័យនោះ តើដូចម្តេច ៗ ការមិនចង់បាន ការមិនជាប់ចំពាក់ សេចក្តីមិនជាប់ចំពាក់ ការមិនត្រេកអរខ្លាំង ការមិនត្រេកត្រអាល សេចក្តីមិនត្រេកត្រអាល ការមិនសំឡឹងចំពោះ គឺអលោភៈ ជាកុសលមូល ណា ក្នុងសម័យនោះ នេះអនភិជ្ឈា កើតមានក្នុងសម័យនោះ ។

(៩១) អព្យាបាទ កើតមានក្នុងសម័យនោះ តើដូចម្តេច ៗ សេចក្តីមិនខឹង ការមិនប្រទូស្ត សេចក្តីមិនប្រទូស្ត ការមិនព្យាបាទ សេចក្តីមិនព្យាបាទ គឺអទោសៈ ជាកុសលមូល ណា ក្នុងសម័យនោះ នេះអព្យាបាទ កើតមានក្នុងសម័យនោះ ។

(៩២) សម្មាទិដ្ឋិ កើតមានក្នុងសម័យនោះ តើដូចម្តេច ៗ បញ្ញា សេចក្តីដឹងសព្វ សេចក្តីពិចារណា សេចក្តីជ្រើសរើស សេចក្តីពិចារណាធម៌ ការកំណត់ ការកត់សំគាល់ សេចក្តីកត់ត្រា ភាពនៃបណ្ឌិត ភាពនៃអ្នកឈ្លាស ភាពនៃបុគ្គលមានសេចក្តីជ្រះស្អាត ភាពនៃបុគ្គលមានសេចក្តីភ្លឺច្បាស់ សេចក្តីគិត សេចក្តីយល់ ធម្មជាតិដូចផែនដី

មេធា បរិណាយិកា វិបស្សនា សម្បជញ្ញំ បតោទោ បញ្ញា បញ្ញិន្ទ្រិយំ បញ្ញាពលំ បញ្ញាសត្ថំ បញ្ញាបាសាទោ បញ្ញាអាលោកោ បញ្ញាឱភាសោ បញ្ញាបជ្ជោតោ បញ្ញារតនំ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ អយំ តស្មិំ សមយេ សម្មាទិដ្ឋិ ហោតិ ។

(៥៣) កតមា តស្មិំ សមយេ ហិរិ ហោតិ ។ យំ តស្មិំ សមយេ ហិរិយតិ ហិរិយិតព្វេន ហិរិយតិ បាបកានំ អកុសលានំ ធម្មានំ សមាបត្តិយា អយំ តស្មិំ សមយេ ហិរិ ហោតិ ។

(៥៤) កតមំ តស្មិំ សមយេ ឱត្តប្បំ ហោតិ ។ យំ តស្មិំ សមយេ ឱត្តប្បតិ ឱត្តប្បិតព្វេន ឱត្តប្បតិ បាបកានំ អកុសលានំ ធម្មានំ សមាបត្តិយា ឥទំ តស្មិំ សមយេ ឱត្តប្បំ ហោតិ ។

ធម្មជាតិកំចាត់កិលេស ធម្មជាតិណែនាំ ធម្មជាតិឃើញច្បាស់ សេចក្តី ដ៏ល្អ សភាពដូចជាជន្លួញ គឺបញ្ញា បញ្ញិន្ទ្រិយ បញ្ញាពលៈ គ្រឿងសស្ត្រាគឺបញ្ញា ប្រាសាទគឺបញ្ញា ពន្លឺគឺបញ្ញា ឱភាសគឺបញ្ញា គ្រឿងឆ្លុះគឺបញ្ញា រតនៈគឺបញ្ញា អមោហៈ ធម្មវិចយៈ សម្មាទិដ្ឋិ ណា ក្នុងសម័យនោះ នេះសម្មាទិដ្ឋិ កើតមានក្នុងសម័យនោះ ។

(៤៣) ហិរិ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ត្រង់ដែល បុគ្គលខ្មាសដោយវត្ថុដែលគួរខ្មាស ខ្មាសដោយការជួបប្រទះនឹងអកុសល-ធម៌ដ៏លាមក ក្នុងសម័យនោះ នេះហិរិ កើតមានក្នុងសម័យនោះ ។

(៤៤) ឱត្តប្បៈ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ត្រង់ ដែលបុគ្គលតក់ស្លុត ដោយវត្ថុដែលគួរតក់ស្លុត តក់ស្លុតដោយការជួប ប្រទះនឹងអកុសលធម៌ដ៏លាមក ក្នុងសម័យនោះ នេះឱត្តប្បៈ កើត មានក្នុងសម័យនោះ ។

(៤៥) កតមា តស្មឹ សមយេ កាយប្បស្សទ្ធិ ហោតិ ។ យា តស្មឹ សមយេ វេទនាក្ខន្ធស្ស សញ្ញាក្ខន្ធស្ស សង្ខារក្ខន្ធស្ស បស្សទ្ធិ បដិប្បស្សទ្ធិ[១] បស្សម្ភនា បដិប្បស្សម្ភនា បដិប្បស្សម្ភិតត្តំ អយំ តស្មឹ សមយេ កាយប្បស្សទ្ធិ ហោតិ ។

(៤៦) កតមា តស្មឹ សមយេ ចិត្តប្បស្សទ្ធិ ហោតិ ។ យា តស្មឹ សមយេ វិញ្ញាណក្ខន្ធស្ស បស្សទ្ធិ បដិប្បស្សទ្ធិ បស្សម្ភនា បដិប្បស្សម្ភនា បដិប្បស្សម្ភិតត្តំ អយំ តស្មឹ សមយេ ចិត្តប្បស្សទ្ធិ ហោតិ ។

(៤៧) កតមា តស្មឹ សមយេ កាយលហុតា ហោតិ ។ យា តស្មឹ សមយេ វេទនាក្ខន្ធស្ស សញ្ញាក្ខន្ធស្ស សង្ខារក្ខន្ធស្ស លហុតា លហុបរិណាមតា អទន្ធនតា អវិត្ថនតា អយំ តស្មឹ សមយេ កាយលហុតា ហោតិ ។

---

១ ឱ. ម. បដិបស្សទ្ធិ ។

(៥៥) សេចក្ដីស្ងប់កាយ កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ សេចក្ដីស្ងប់ សេចក្ដីរម្ងាប់ ការស្ងប់ ការរម្ងាប់ សេចក្ដីស្ងៀមស្ងាត់ ណា នៃវេទនាខន្ធ នៃសញ្ញាខន្ធ នៃសង្ខារក្ខន្ធ ក្នុងសម័យនោះ នេះសេចក្ដីស្ងប់កាយ កើតមានក្នុងសម័យនោះ ។

(៥៦) សេចក្ដីស្ងប់ចិត្ត កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ សេចក្ដីស្ងប់ សេចក្ដីរម្ងាប់ ការស្ងប់ ការរម្ងាប់ សេចក្ដីស្ងៀមស្ងាត់ ណា នៃវិញ្ញាណក្ខន្ធ ក្នុងសម័យនោះ នេះសេចក្ដីស្ងប់ចិត្ត កើតមានក្នុងសម័យនោះ ។

(៥៧) សេចក្ដីស្រាលកាយ កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ សេចក្ដីស្រាល ការបង្អោនទៅរហ័ស សេចក្ដីមិនយឺតយូរ សេចក្ដីមិនទំរន់ ណា នៃវេទនាខន្ធ នៃសញ្ញាខន្ធ នៃសង្ខារក្ខន្ធ ក្នុងសម័យនោះ នេះសេចក្ដីស្រាលកាយ កើតមានក្នុងសម័យនោះ ។

(៥៨) កតមា តស្មឹ សមយេ ចិត្តលហុតា ហោតិ ។ យា តស្មឹ សមយេ វិញ្ញាណក្ខន្ធស្ស លហុតា លហុបរិណាមតា អទន្ធនតា អវិត្ថនតា អយំ តស្មឹ សមយេ ចិត្តលហុតា ហោតិ ។

(៥៩) កតមា តស្មឹ សមយេ កាយមុទុតា ហោតិ ។ យា តស្មឹ សមយេ វេទនាក្ខន្ធស្ស សញ្ញាក្ខន្ធស្ស សង្ខារក្ខន្ធស្ស មុទុតា មទ្ទវតា អកក្ខលតា អកថិនតា អយំ តស្មឹ សមយេ កាយមុទុតា ហោតិ ។

(៦០) កតមា តស្មឹ សមយេ ចិត្តមុទុតា ហោតិ ។ យា តស្មឹ សមយេ វិញ្ញាណក្ខន្ធស្ស មុទុតា មទ្ទវតា អកក្ខលតា អកថិនតា អយំ តស្មឹ សមយេ ចិត្តមុទុតា ហោតិ ។

